ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ត្រីមាសទី៣ ឆ្នាំ២០២៣

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក
ស
វ



E
C
O
S
O
C
C


ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

## គតិបណ្ឌិតសម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**« មិនបោះបង់នរណាម្នាក់ ឬទីកន្លែងណាមួយចោលទេ**
**Leave no One and no Place Behind »**

កិច្ចប្រជុំកំពូលអាស៊ាន លើកទី៤៣ នៅប្រទេស Indonesia

**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង

- យឹម ណុលសន

និពន្ធនាយក

- អ៊ីវ ចុង

ការិយាល័យនិពន្ធ

- នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត

- លី គឹមសុខ

- ឆយ អូន

- ទីប្រឹក្សាបច្ចេកទេស

- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

អ្នកចាត់ចែងផលិត

- ប៉ិច សុខា

- អ៊ិន គុលា

អ្នកចែកផ្សាយ

- អៀង រដ្ឋា

- សេក វុទ្ធី

ការីកុំព្យូទ័រ

- អេង វត្តមុនី

- សយ វាស្នា

- យឹម ច័ន្ទតារា

# មាតិកា

**ទំព័រ**


I- បទអត្ថាធិប្បាយ សញ្ញាណអរិយធម៌ ៖ គំនិត ធាតុ វិវត្តន៍ អរិយធម៌ សំខាន់ៗ ១-៤

II- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ឆ្នាំ២០២៣-២០២៨ ៥-៦

III- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំឆមាសទី១ ឆ្នាំ២០២៣ ៧-១៥

IV- បទវិភាគ៖

- សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ៖ ការប្រកាន់យកប្រព័ន្ធពហុភាគី ដើម្បីលើកកម្ពស់សន្តិភាព ទាំងក្នុងប្រទេស និងជុំវិញពិភពលោក ១៦

V- នាទីសិក្សា-ស្រាវជ្រាវ

- ការសិក្សាស្រាវជ្រាវសាគរសាស្ត្រ និងធនធានជលផលនៅសមុទ្រកម្ពុជាឆ្នាំ១៩៨៣-១៩៨៦ (ត) ១៧-២៦

VI- នាទីវប្បធម៌

១- ជ្រុងមួយនៃភាសាខ្មែរ : ចម្ងល់យើងចំពោះពាក្យខ្មែរមាន « វ » ២៧-២៨

២- ស្វែងយល់ពី កំណើតសីលធម៌ ២៩-៣១

VII- នាទីកំណាព្យ

- ពាក្យកាព្យក្រមង៉ុយប្រដៅសិស្ស (បទពាក្យ៧) ៣២

VIII- នាទីកំសាន្ត

- កម្រងនវកថា : មួយពព្រិចភ្នែក ! ៣៣-៣៥

# សញ្ញាណអរិយធម៌ ៖ គំនិត ធាតុ វិវត្តន៍ អរិយធម៌សំខាន់ៗ

មុននឹងលើកយកអរិយធម៌ទាំងឡាយក្នុងលោកមកសិក្សា គួរតែយើងវែកញែកបញ្ជាក់ឱ្យបានច្បាស់លាស់សិនថា តើអ្វីទៅដែលគេនិយមហៅថា «អរិយធម៌»នោះ ?

អរិយធម៌បានកើតមកព្រមគ្នាជាមួយមនុស្ស តែវាជាសញ្ញាណថ្មីមួយក្នុងប្រវត្តិនៃគំនិតរបស់មនុស្ស បានន័យថា សញ្ញាណនៃអរិយធម៌ទើបតែបានកើតឡើងនៅពេលដែលគេទទួលស្គាល់ថា ការសិក្សាអំពីទំនៀមទម្លាប់ របៀបរស់នៅ ជំនឿ ... នៃជនជាតិនីមួយៗ មានសារៈសំខាន់ជាងការសិក្សាអំពីព្រឹត្តិការណ៍ប្រវត្តិនៃជនជាតិនោះទៅទៀត។ អរិយធម៌ជាសញ្ញាណស្មុគស្មាញព្រោះធាតុដែលផ្សំផ្សំឱ្យកើតបានជាអរិយធម៌មួយៗមានច្រើនណាស់ ហើយវិញម្យ៉ាងទៀត ធាតុទាំងនោះក៏ពុំដូចគ្នា ពីអរិយធម៌មួយទៅអរិយធម៌មួយទៀតដែរ។ មិនតែប៉ុណ្ណោះ អរិយធម៌ទាំងឡាយក្នុងលោក សុទ្ធតែមានជីវិត និងវិវត្តន៍រៀងៗខ្លួនរបស់វាថែមទៀត។ រីឯពាក្យដែលគេបានបង្កើតឡើងក្នុងភាសានីមួយៗ ដើម្បីយកមកប្រើសម្គាល់«អរិយធម៌» នោះទៀតសោត ក៏ជាពាក្យថ្មីហើយតែងមានន័យផ្លាស់ប្តូរ ទៅតាមកាលសម័យទៀតផង។

## ១. គំនិត «អរិយធម៌» និងពាក្យ «អរិយធម៌» .-

«គំនិតអរិយធម៌» និង «អរិយធម៌» ទើបតែនឹងកើតឡើងទេ ហើយកើតឡើងក្នុងពេលជាមួយគ្នាទៀត។

ក្នុងភាសាបារាំង គេសង្កេតឃើញលោក ម៉ុងតែញ ( Montaigne ) ប្រើពាក្យ « civilise' » ឯលោកអាឡំប៊ែ ( Alembert ) និង ឌីដឺរ៉ូ ( Diderot ) បានប្រើពាក្យ «civilite'» ក្នុង «Encyclope'die» ។ គឺ មីរ៉ាបូ ( Mirabeau ) ដែលបានយកពាក្យ«civilisation»មកប្រើមុនគេបង្អស់នៅឆ្នាំ១៧៥៦ ហើយរហូតមកដល់ចុងគ.ស.វ.ទី១៨ ទើបជនជាតិបារាំងបាននិយមយកពាក្យនេះមកប្រើច្រើន។លុះដល់ឆ្នាំ១៨៣៥ទើបគេឃើញមានបញ្ចូលពាក្យ «civilisation» ទៅក្នុងវចនានុក្រមនៃបណ្ឌិតសភា។ដូចពាក្យថ្មីៗឯទៀតដែរ គេបានបង្កើតពាក្យនេះឡើងសម្រាប់យកមកប្រើក្នុងក្នុងភាសាមនុស្ស ដើម្បីសម្គាល់គំនិតថ្មី ដែលមនុស្សបានគិតឃើញនិងបញ្ចេញមក។ នៅប្រទេសបារាំង ពាក្យ «civilisation» បានកើតឡើងដោយគេត្រូវការពាក្យនេះ សម្រាប់ប្រើសម្គាល់ «ស្ថានភាពអ្នកក្រុង» ដោយប្រៀបធៀបទៅនឹង«ស្ថានភាពអ្នកស្រែ» ឬ សម្គាល់ «ស្ថានភាពអ្វីដែលគេបានរៀបចំ ឱ្យមានរបៀបរៀបរយ» ដោយប្រៀបធៀបទៅនឹង «អ្វីដែលឋិតនៅក្នុងស្ថានភាពព្រៃផ្សៃនៅឡើយ» ។

ន័យទីមួយស្របនឹងឫសគល់ដើមរបស់ពាក្យ «civilisation» ដែលបានក្លាយមកពីពាក្យឡាតាំង «civitas» ប្រែថាក្រុងឬបុរី ន័យទីពីរមានលក្ខណៈទូលំទូលាយជាង តែន័យដើមទាំងពីរនេះឋិតនៅលើការប៉ាន់ប្រមាណអំពីតម្លៃនៃអរិយធម៌ដោយយកអរិយធម៌ផ្សេងៗមកប្រៀបធៀបគ្នា ហើយគេនិយមទទួលស្គាល់ថាជាអរិយធម៌ចំពោះតែអរិយធម៌ណាដែលល្អប្រសើរប៉ុណ្ណោះ។ ដោយផ្អែកទៅលើន័យដើមនេះ ជនជាតិអឺរ៉ុបយល់ឃើញថាមានតែអរិយធម៌អឺរ៉ុបមួយទេដែលអាចយកពាក្យ«civilisation»មកប្រើសម្គាល់បាន។ យ៉ាងណាមិញ ជនជាតិអឺរ៉ុបបានទុកដាក់ថាមានតែខ្លួនគេទេដែលមាន«ស្ថានភាព»មាន«កម្រិត» សមនឹងពាក្យ «civilisation» ហើយចាត់ទុកជនជាតិដទៃទៀតថាមាន «ស្ថានភាពព្រៃផ្សៃ» នៅឡើយក្នុងសម័យជាមួយគ្នានោះ។ គឺក្នុងគោលគំនិត ដែលគេ

បានបង្កើតពាក្យ»civilisation» នេះឡើង ហើយគឺគំនិតនេះទៀតដែលទ្រទ្រង់នយោបាយអាណានិគមរបស់ជនជាតិអឺរ៉ុប ពីព្រោះគំនិតនេះធ្វើឱ្យគេមានជំនឿថា ជនជាតិអឺរ៉ុប មានករណីយកិច្ចពិសេសនឹងយក«អរិយធម៌» ទៅផ្សព្វផ្សាយដល់ជនជាតិដទៃទៀត ដើម្បីឱ្យជនជាតិអន់ខ្សោយទាំងនោះបានស្គាល់ពី«អរិយធម៌»ផង។ ក៏ប៉ុន្តែ គំនិត«អរិយធម៌» បានវិវត្តហើយពាក្យ«civilisation»ក៏ត្រូវផ្លាស់ប្តូរន័យទៅតាមវិវត្តន៍នោះដែរ។យ៉ាងណាមិញចាប់តាំងពីចុងគ.ស.វ.ទី១៩អឺរ៉ុបដែលធ្លាប់តែមានប្រៀបលើប្រទេសដទៃទៀតក្នុងវិស័យសេដ្ឋកិច្ចនិងនយោបាយនោះបានសង្កេតឃើញឥទ្ធិពលរបស់ខ្លួនចុះអន់ថយជាលំដាប់ ហើយស្របគ្នានឹងស្ថានការណ៍នេះ ឧត្តមភាពនៃអរិយធម៌អឺរ៉ុប ក៏បានស្រុតចុះទៅជាមួយផងដែរ។ ម្យ៉ាងវិញទៀត ទំនាក់ទំនងរវាងអឺរ៉ុបនឹងស្រុកចំណុះ ហើយការរីកចម្រើនដ៏សម្បើមនៃវិទ្យាសាស្ត្រថ្មីៗ ដូចជាជាតិពន្ធុវិទ្យា សង្គមវិទ្យា បុរាណវិទ្យាជាដើម។ នៅដើមគ.ស.វ.ទី២០បានបង្ហាញឱ្យឃើញថានៅក្នុងលោកយើងនេះ ក្រៅពីអរិយធម៌អឺរ៉ុប នៅមានអរិយធម៌ផ្សេងៗទៀតជាច្រើន ហើយអរិយធម៌ទាំងនោះ ក៏មានតម្លៃនិងលក្ខណៈពិសេសរបស់គេដែរ។ គឺកត្តាទាំងអស់នេះហើយ ដែលធ្វើឱ្យគេលែងនិយមថា អរិយធម៌អឺរ៉ុបវិសេសវិសាលជាងគេ ហើយពាក្យ «civilisation» ដែលគេបានបង្កើតឡើងសម្រាប់តែអរិយធម៌អឺរ៉ុបនោះ បានត្រូវគេយកមកប្រើសម្រាប់សម្គាល់អរិយធម៌ទូទៅក្នុងលោកដោយលែងគិតអំពីតម្លៃទៀតហើយ ព្រោះអរិយធម៌នីមួយៗសុទ្ធតែមានតម្លៃពិសេសផ្ទាល់ខ្លួន ដែលគេមិនអាចនឹងយកទៅប្រដូច ឬចាត់ថ្នាក់ជាមួយនឹងតម្លៃនៃអរិយធម៌មួយទៀតបានឡើយ។គឺក្នុងទស្សនៈនេះហើយដែលលោក លីត្រេ (Littre') បានពន្យល់ពាក្យ«civilisation» ថាជា «លក្ខណៈរួមគ្នាទាំងអស់របស់សង្គមណាមួយក្នុងដែនដីណាមួយ ក្នុងពេលណាមួយ នៃប្រវត្តិរបស់ខ្លួន» ក្នុងន័យនេះ ពាក្យ«civilisation» អាចយកទៅប្រើជាមួយនឹងអរិយធម៌ណាក៏បានហើយ ក្នុងគោលគំនិតនេះ នយោបាយអាណានិគមរបស់អឺរ៉ុប ក្នុងគោលបំណងផ្សព្វផ្សាយអរិយធម៌ ក៏លែងមានន័យតតទៅទៀតដែរ ។

ចំណែកក្នុងភាសាខ្មែរវិញ ពាក្យ«អរិយធម៌» ទើបនឹងបានកើតឡើងក្នុងសម័យទំនើបនេះទេ ។ យើងបានប្រែពាក្យ«civilisation» ថា «អរិយធម៌ ឬ អារ្យធម៌» ។ សម្តេចព្រះសង្ឃរាជ ជួន ណាត បានពន្យល់ពាក្យ«អរិយធម៌ ឬ អារ្យធម៌» ក្នុងវចនានុក្រមខ្មែរថា «ធម៌ដែលនាំឱ្យកើតសេចក្តីសុខចម្រើន ធម៌របស់អរិយជន ទំនៀម សណ្តាប់ល្អ សណ្តាប់ធ្នាប់ ឬ បែបបទរៀបរយ» ។ ការពន្យល់នេះបានប្រមូលយកន័យជាច្រើនរបស់ពាក្យអរិយធម៌មកបញ្ចូលគ្នា ។

## ២. ធាតុនៃអរិយធម៌ .-

អរិយធម៌នីមួយៗ អាចមានទិដ្ឋភាពរូបនិយម ( Aspects Mate'rialiste ) និងទិដ្ឋភាពគំនិតនិយម (Aspects spiritualisme ) ។ ទិដ្ឋភាពរូបនិយម សំដៅទៅលើវិធីនិងបច្ចេកទេសផ្សេងៗដែលមនុស្សយកមកប្រើសម្រាប់សម្របសម្រួល ឬសម្រាប់ប្រយុទ្ធនឹងធម្មជាតិដើម្បីទាញយកប្រយោជន៍ឱ្យបានច្រើនជាទីបំផុត ។ ចំណែកទិដ្ឋភាពគំនិតនិយមវិញ សំដៅទៅលើជំនឿ សីលធម៌ សិល្បៈជាដើម ដែលមនុស្សខំសម្រិតសម្រាំង ដើម្បីសុខដុមរមនាក្នុងសង្គម ។ ការញែកអរិយធម៌ជាពីរទិដ្ឋភាពឱ្យដាច់ស្រឡះពីគ្នា មិនមែនជាការងាយទេ ពីព្រោះធាតុទាំងឡាយដែលផ្សំផ្គុំឱ្យកើតជាអរិយធម៌ឡើងអាចមានលក្ខណៈជារូបនិយមផង និងគំនិតនិយមផង ។ ធាតុទាំងឡាយនោះគឺ ៖

ក. របៀបរស់នៅ : ធាតុនេះនាំឱ្យនឹកឃើញដល់របៀបរស់នៅផ្សេងៗគ្នាតាំងពីរបៀបរស់នៅដោយរើស ឬបេះផ្លែឈើធ្វើជាអាហារ រហូតដល់របៀបរស់

នៅដោយមានឧស្សាហកម្មជាមូលដ្ឋាន ។ គេច្រើនយករបៀបរស់នៅរបស់ចរកជន(nomades) ទៅប្រៀបធៀបនឹងរបៀបរស់នៅរបស់ពួក និសិទ្នជន(se'dentaires) ដោយគិតទៅដល់ចំណីអាហារ សម្លៀកបំពាក់ ជម្រក ឬ របៀបព្យាបាលជំងឺ ជាដើម នៃអរិយធម៌ណាមួយ ។

ខ.បច្ចេកទេសៈធាតុនេះនាំឱ្យនឹកឃើញដល់របៀបបង្កើតផលដូចជា ប្រមាញ់ នេសាទ ចិញ្ចឹមសត្វ កសិកម្ម ឧស្សាហកម្ម ជាដើម និងសម្ភារៈប្រើប្រាស់ដែលជាមធ្យោបាយសម្រាប់បង្កើតផលដូចជាកាំបិត ពូថៅ ចាន ឆ្នាំង ន័ង្គល រនាស់ យានជំនិះ គ្រឿងចក្រ គ្រឿងអាវុធ ជាដើម នៃអរិយធម៌ណាមួយ ។

គ.ទម្រង់នយោបាយៈធាតុនេះនាំឱ្យនឹកឃើញដល់លទ្ធិនិងរបបនយោបាយផ្សេងៗ ដូចជាលទ្ធិផ្តាច់ការលទ្ធិប្រជាធិបតេយ្យស្ថាប័ននយោបាយរបបរាជានិយម ឬសាធារណរដ្ឋនិយមជាដើម នៃអរិយធម៌ណាមួយ ។

ឃ. ទម្រង់សេដ្ឋកិច្ចៈធាតុនេះនាំឱ្យនឹកឃើញដល់ទម្រង់កសិកម្មឧស្សាហកម្មនិងពាណិជ្ជកម្មដែលមានមូលដ្ឋានផ្សេងៗគ្នា ដូចជារបបទាសភាពនិយម មូលធននិយម ឬ កុំមុយនីសនិយមជាដើម នៃអរិយធម៌ណាមួយ ។

ង. ទម្រង់សង្គម : ធាតុនេះនាំឱ្យឃើញដល់ស្ថាប័នសង្គម ដូចជាគ្រួសារ អាពាហ៍ពិពាហ៍ មត៌ក ការងារ សង្គមកិច្ច ឬទំនាក់ទំនងរវាងមនុស្សក្នុងសង្គមជាតិ និងសង្គមអន្តរជាតិជាដើម នៃអរិយធម៌ណាមួយ ។

ច. សាសនានិងសីលធម៌ : ធាតុនេះនាំឱ្យនឹកឃើញដល់ទំនៀមទម្លាប់និងជំនឿផ្សេងៗ ដូចជាជឿទៅលើខ្មោចព្រាយបិសាចឬជំនឿជាបែបសាសនាជាដើម នៃអរិយធម៌ណាមួយ ។ ទំនៀមទម្លាប់និងជំនឿនេះហើយ ដែលអាចជាមូលដ្ឋាននៃសីលធម៌របស់អរិយធម៌ណាមួយ។ចំពោះសង្គមជាតិណាដែលគ្មានទៅលើសាសនាធាតុនេះមិនជាសំខាន់ទេនៅក្នុងអរិយធម៌ នៃសង្គមជាតិនោះ ។ ក៏ប៉ុន្តែ ចំពោះអរិយធម៌ខ្លះទៀត ដូចជាអរិយធម៌អ៊ីស្លាមជាដើម ធាតុនេះត្រឡប់ទៅជាកត្តាសំខាន់បំផុត ។

ឆ.សមត្ថភាពខាងបញ្ញានិងសិល្បៈៈធាតុនេះនាំឱ្យនឹកឃើញដល់ពុទ្ធិផ្សេងៗ ដែលមនុស្សក្នុងសង្គមជាតិណាមួយបានបង្កើតឡើង ដូចជាភាសា អក្សរ ល្បែង កីឡា ទស្សនវិជ្ជា វិទ្យាសាស្ត្រគ្រប់បែប ឬសិល្បៈគ្រប់ប្រភេទនៃអរិយធម៌ណាមួយជាដើម ។ គឺធាតុទាំងអស់នេះហើយដែលផ្សំផ្សំគ្នាទៅកើតបានជា«រូបរាង» និង«ព្រលឹង» នៃអរិយធម៌មួយឡើង ។ ក៏ប៉ុន្តែ អរិយធម៌នីមួយៗមិនមែនសុទ្ធតែមានគ្រប់តែធាតុទាំងអស់ ខាងលើនេះឡើយ ។អរិយធម៌ខ្លះមានធាតុនេះច្រើនជាង អរិយធម៌ខ្លះទៀតមានធាតុនោះច្រើនជាងទៅវិញ ។អាស្រ័យហេតុនេះហើយ បានជាគេអាចនិយាយថា អរិយធម៌អាស៊ីជាអរិយធម៌គំនិតនិយម(civilisation spiritualisme) រីឯអរិយធម៌អឺរ៉ុបជាអរិយធម៌រូបនិយម(civilisation mate'rial-isme) ។

### ៣. វិវត្តន៍នៃអរិយធម៌ .-

គេច្រើនតែចាត់ទុកអរិយធម៌ដូចជាវត្ថុមានជីវិត ព្រោះអរិយធម៌បានកើតឡើង បានរីកចម្រើនហើយ បានចុះអន់ថយរួចវិនាសសាបសូន្យទៅវិញ។ ធាតុទាំងឡាយដែលផ្សំផ្សំគ្នាឱ្យកើតជាអរិយធម៌ណាមួយ មិនមែនចេះតែកកើតឡើងដោយចៃដន្យ ឬឥតសមហេតុផលនោះទេ ។ ធាតុទាំងឡាយនោះសុទ្ធតែបានផ្សំផ្សំគ្នាឡើងម្តងបន្តិចៗអស់រយៈពេលយ៉ាងយូរ ជួនកាលរាប់សតវត្សក្នុងប្រវត្តិរបស់ខ្លួនទម្រាំនឹងកើតបានជាអរិយធម៌មួយឡើង ។ ក្នុងការផ្សំផ្សំនេះគេច្រើនសង្កេតឃើញធាតុខ្លះបានមករួមផ្គុំជាមួយនឹងធាតុខ្លះទៀត ជួនតិច ជួនច្រើន តែជាធាតុដ៏សំខាន់ ហើយដែលជាធាតុមូលដ្ឋាននៃអរិយធម៌

នោះឯង ។ ឧទាហរណ៍ : អរិយធម៌អ៊ីស្លាមដែលមានសាសនាអ៊ីស្លាមជាធាតុសំខាន់ឬអរិយធម៌អាស៊ីដែលមានធាតុផ្នែកគំនិតនិយមជាធាតុដើម ។ ចំណែកឯការវិនាសសាបសូន្យនៃអរិយធម៌វិញ អាចប្រព្រឹត្តទៅដោយសន្សឹមៗដូចកាលដែលអរិយធម៌នោះបានកកើតឡើងដូច្នោះដែរ (ស្ទើរតែគ្រប់អរិយធម៌ទាំងអស់) ឬដោយទាន់ហន់ភ្លាមៗ (អរិយធម៌ក្រិច)។ ការវិនាសសាបសូន្យយ៉ាងរួសរាន់បែបនេះ ច្រើនបណ្តាលមកពីបាតុភូតធម្មជាតិ ដូចជា អគ្គីភ័យ ទឹកជំនន់ ឬរញ្ជួយព្រះធរណីជាដើម ។ សេចក្តីរៀបរាប់ខាងលើបានបញ្ជាក់ថា អរិយធម៌នីមួយៗ សុទ្ធតែមានវិវត្តន៍ជានិច្ចនិរន្តរ៍ ហើយក្នុងវិវត្តន៍របស់ខ្លួនតាំងពីចាប់កំណើតឡើងរហូតដល់ស្លាប់ទៅវិញ អរិយធម៌នីមួយៗតែងតែជួបប្រទះនឹងសម័យចម្រើនលូតឡាស់និងសម័យចុះដុនដាបជាលំដាប់លំដោយ តែមួយលើកក៏មាន ច្រើនលើកក៏មាន។ វិវត្តន៍នៃអរិយធម៌អាចប្រព្រឹត្តទៅដោយសន្សឹមៗ រហូតដល់នាំឱ្យគេមើលទៅឃើញហាក់ដូចជានៅនឹងថ្កល់គ្មានវិវត្តន៍សោះ (អរិយធម៌ចិនរហូតដល់ឆ្នាំ១៩១១) ឬដោយឆាប់រហ័ស(អរិយធម៌អឺរ៉ុបតាំងពីឆ្នាំ១៨៥០)។ ល្បឿនវិវត្តន៍នៃអរិយធម៌នីមួយៗ អាស្រ័យទៅលើថាមភាពនៃអរិយធម៌នោះឬជួនកាលអាស្រ័យទៅលើឥទ្ធិពលនៃអរិយធម៌ដទៃ ដែលជ្រៀតចូលមក ហើយញ៉ាំងវិវត្តន៍ជាធម្មតានៃអរិយធម៌នោះ ឱ្យផ្លាស់ប្តូរទៅតាមចង្វាក់ថ្មី ។ អរិយធម៌សំខាន់ៗទាំងឡាយក្នុងលោកសុទ្ធតែបានទទួលឥទ្ធិពលពីគ្នាទៅវិញទៅមកជានិច្ច។ឯទំនាក់ទំនងរវាងអរិយធម៌ក៏អាចផ្តល់វិបាកអាក្រក់ឬល្អឱ្យគ្នាទៅវិញទៅមកដែរ។កត្តាដែលជំរុញឱ្យមានទំនាក់ទំនងរវាងអរិយធម៌ទាំងឡាយក្នុងលោក គឺសង្គ្រាមជំនួញ សាសនា ដំណើរអាណានិគម ការរីកចម្រើននៃវិទ្យាសាស្ត្រ ការសិក្សាស្រាវជ្រាវ និងការលូតលាស់យ៉ាងឆាប់រហ័សខាងផ្នែកមធ្យោបាយគមនាគមន៍ក្នុងការប្តូរផ្តល់ទៅវិញទៅមកនូវពត៌មានគ្រប់បែបយ៉ាង ។ គឺកត្តាទាំងនេះហើយ ដែលជាបុព្វហេតុច្បងសម្រាប់ញ៉ាំងវិវត្តន៍នៃអរិយធម៌ឱ្យមានល្បឿនលឿនឡើងថែមទៀត ហើយដែលបណ្តាលឱ្យអរិយធម៌ទាំងឡាយបានឆ្លងព្រំដែនរបស់ខ្លួន ទៅផ្សព្វផ្សាយក្នុងសកលលោកយើងនេះ ។

ដូចនេះវិវត្តន៍នៃអរិយធម៌នីមួយៗត្រូវអាស្រ័យមួយផ្នែកយ៉ាងធំ ទៅលើវិវត្តន៍នៃប្រវត្តិសាស្ត្ររបស់មនុស្សនៃសង្គមជាតិណាមួយឬនៃមនុស្សជាតិទូទៅ។

## ៤. អរិយធម៌សំខាន់ៗក្នុងលោក .-

ដោយអរិយធម៌មានចំនួនច្រើន ហើយអរិយធម៌ទាំងនោះច្រើនតែមានទំនាក់ទំនងរវាងគ្នាផងការចែកអរិយធម៌ឱ្យដាច់ចេញពីគ្នាមិនមែនជាការងាយឡើយ ។ ប៉ុន្តែ ដើម្បីសម្រួលដល់ការសិក្សា គេអាចចែកអរិយធម៌សំខាន់ៗក្នុងលោក ជាប្រាំក្រុមដូចតទៅ :

១. អរិយធម៌បស្ចិម (អឺរ៉ុបខាងលិច និងអាមេរិក )
២. អរិយធម៌អាស៊ី (អាស៊ីចុងបូព៌ា អាស៊ីភាគអាគ្នេយ៍ ឥណ្ឌា)
៣. អរិយធម៌អ៊ីស្លាម (ប្រទេសកាន់សាសនាអ៊ីស្លាម)
៤.អរិយធម៌សង្គមនិយម (ប្រទេសសង្គមនិយមទាំងអស់)
៥.អរិយធម៌អាហ្វ្រិកខ្មៅ(អាហ្វ្រិកអេក្វាទ័រនិងអាហ្វ្រិកចន្លោះខ្សែនិរត្ត) ។

រួមសេចក្តីមក គំនិត«អរិយធម៌» បានផ្លាស់ប្តូរពីន័យចង្អៀតចង្អល់ទៅន័យទូលំទូលាយ ស្របនឹងវិវត្តន៍ទូទៅ នៃគំនិតដែលមានដំណើរពីអាត្មា ឬប្រយោជន៍និយមទៅវិទ្យាសាស្ត្រ ឬសកលនិយមរបស់មនុស្សជាតិ ។ ចំណែកអរិយធម៌ខ្លួនឯងវិញ គេសង្កេតឃើញថា អរិយធម៌ទាំងអស់ក្នុងលោកសុទ្ធតែមានប្រវត្តិផ្ទាល់របស់ខ្លួនហើយក្នុងវិវត្តន៍តាមបែបបទផ្ទាល់របស់ខ្លួននោះ អរិយធម៌នីមួយៗបានចម្រើនរុងរឿង និងខ្ពង់ខ្ពស់បំផុតនៅពេលណាដែលធាតុទាំងឡាយដែលជាគ្រឿងផ្សំនៃអរិយធម៌នោះបានមករួបរួមរលាយចូលគ្នាយ៉ាងសុខដុមរមនាបំផុត។

**កម្រងទស្សនៈប្លែកៗ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង**

## គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ឆ្នាំ២០២៣-២០២៨

រាជរដ្ឋាភិបាលកម្ពុជា បានផ្តោតការយកចិត្តទុកដាក់ក្នុងការរៀបចំប្រព័ន្ធច្បាប់ និងបទដ្ឋានគតិយុត្ត ស្របតាមគោលការណ៍ជាតិ និងអន្តរជាតិ។ ច្បាប់កម្មសិទ្ធិបញ្ញាជាច្រើនត្រូវបានរៀបចំឡើងដើម្បីផ្តល់កិច្ចការពារកម្មសិទ្ធិបញ្ញាឱ្យមានប្រសិទ្ធភាពនិងស្របតាមកិច្ចព្រមព្រៀងអន្តរជាតិដែលជាការផ្តល់ទំនុកចិត្តដល់អ្នកវិនិយោគ ជំរុញពាណិជ្ជកម្ម ការស្រាវជ្រាវ និងការអភិវឌ្ឍនៅកម្ពុជា។

សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីកម្មសិទ្ធិបញ្ញាបង្កើតឡើងឱ្យស្របទៅនឹងកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា គោលនយោបាយនេះ មានចក្ខុវិស័យអភិវឌ្ឍន៍ប្រព័ន្ធកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជាឱ្យក្លាយទៅជាកម្លាំងចលករក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្ម ឧស្សាហកម្ម វប្បធម៌ ទេសចរណ៍ កសិកម្ម និងសង្គម ហើយដែលមានគោលបំណងលើកកម្ពស់កិច្ចការពារកម្មសិទ្ធិបញ្ញា កេរ្តិ៍ឈ្មោះ ម៉ាក់ និងផលិតផលរបស់ព្រះរាជាណាចក្រកម្ពុជា បង្កើតស្នាដៃការពារសិទ្ធិអ្នកនិពន្ធ តក្កកម្ម ធនធានពន្ធុ ចំណេះដឹងជាប្រពៃណី និងវិញ្ញាត្តិវប្បធម៌ ជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញាដើម្បីលើកកម្ពស់ ការស្រាវជ្រាវ ការអភិវឌ្ឍ ការបង្កើតផលិតផល បច្ចេកវិទ្យា គំនិតច្នៃប្រឌិត ការបង្កើតថ្មី ព្រមទាំងឧស្សាហកម្មវប្បធម៌ឱ្យឆ្លើយតបទៅនឹងបរិបទសេដ្ឋកិច្ចនិងសង្គមឌីជីថល និងបដិវត្តឧស្សាហកម្មជំនាន់ទី៤ រួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០៥០។

គោលនយោបាយជាតិ ស្តីពីកម្មសិទ្ធិបញ្ញា មានគោលដៅលើកកម្ពស់ប្រព័ន្ធកម្មសិទ្ធិបញ្ញា ក្នុងការអភិវឌ្ឍវិស័យសំខាន់ៗរួមមាន កសិកម្ម វប្បធម៌ អប់រំ និងការលើកកម្ពស់ចំណេះដឹងសាធារណៈ សុខាភិបាល ពាណិជ្ជកម្ម ឧស្សាហកម្ម ទេសចរណ៍ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដោយប្រើប្រាស់យុទ្ធសាស្ត្រ (១)រៀបចំបទប្បញ្ញត្តិនិងលិខិតបទដ្ឋានគតិយុត្តទាក់ទងកម្មសិទ្ធិកញ្ញា ដោយអនុលោមតាមកិច្ចព្រមព្រៀងអន្តរជាតិសម្រាប់ផ្តល់កិច្ចការពារនិងលើកកម្ពស់កម្មសិទ្ធិញ្ញា ប្រកបដោយប្រសិទ្ធភាព ដោយផ្តល់សមភាពនៃផលប្រយោជន៍ម្ចាស់សិទ្ធិ និងផលប្រយោជន៍សាធារណៈ ដើម្បីលើកកម្ពស់សេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកវិទ្យា វប្បធម៌ និងផ្តល់ជំនឿទុកចិត្តដល់អ្នកវិនិយោគ (២)ធ្វើទំនើបកម្មប្រព័ន្ធរដ្ឋបាលនិងការគ្រប់គ្រងដើម្បីពង្រឹងស្ថាប័ន ក្នុងការគ្រប់គ្រងកម្មសិទ្ធិបញ្ញាឱ្យមានប្រសិទ្ធភាពនិងប្រព័ន្ធកម្មសិទ្ធិបញ្ញាឱ្យមានតុល្យភាពដោយលើកកម្ពស់ការផ្តល់សេវាចុះបញ្ជី ជំរុញការចុះបញ្ជី ផ្តល់កិច្ចការពារកម្មសិទ្ធិបញ្ញានិងការបង្កើតទិន្នន័យសម្រាប់ការផ្តល់ព័ត៌មានកម្មសិទ្ធិបញ្ញាក្នុងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមជំរុញបច្ចេកវិទ្យានិងនវានុវត្តន៍នៅកម្ពុជា (៣)អភិវឌ្ឍមូលធនមនុស្សនៃស្ថាប័នសាធារណៈ អភិវឌ្ឍធនធានមនុស្ស លើកកម្ពស់សមត្ថភាពគ្រូបង្គោលលើជំនាញកម្មសិទ្ធិបញ្ញា (៤)ផ្សព្វផ្សាយ និងលើកកម្ពស់ការអប់រំនិងចំណេះ

ដឹងសាធារណៈអំពីកម្មសិទ្ធិបញ្ញា សម្រាប់ផលយោជន៍សេដ្ឋកិច្ចសង្គម (៥)បង្កើតយន្តការពង្រឹងការអនុវត្តច្បាប់ការដោះស្រាយវិវាទកម្មសិទ្ធិបញ្ញាឱ្យមាន ប្រសិទ្ធភាពដើម្បីប្រយុទ្ធប្រឆាំងនិងការរំលោភបំពានកម្មសិទ្ធិបញ្ញា ដើម្បីកសាងសង្គមមួយមានជំនឿទុកចិត្ត និងការគោរពកម្មសិទ្ធិបញ្ញា និង(៦)ធ្វើពាណិជ្ជូបនីយកម្មកម្មសិទ្ធិបញ្ញា ដើម្បីទទួលបានតម្លៃសេដ្ឋកិច្ចសម្រាប់កម្មសិទ្ធិបញ្ញា។

គោលនយោបាយនេះបានឆ្លងកិច្ចប្រជុំផ្ទៃក្នុងក្រុម២នៃក.ស.វ. កាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣ ឆ្លងកិច្ចប្រជុំបច្ចេកទេសថ្ងៃទី២៥ខែឧសភាឆ្នាំ២០២៣ ដឹកនាំអង្គប្រជុំដោយសហប្រធាន ឯកឧត្តម **នរ៉ាណា ឫទ្ធិ អានន្ទជាយ៉ាត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអនុប្រធាន ក.ស.វ. ទទួលបន្ទុកក្រុម២ និង ឯកឧត្តម **លីវ សុវណ្ណា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់តំណាងក្រសួងសាមីដោយឯកឧត្តម **អ៊ុក ប្រជា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។

ជារួមគោលនយោបាយជាតិ ស្តីពីកម្មសិទ្ធិបញ្ញាជាផែនទីបង្ហាញផ្លូវសម្រាប់លើកកម្ពស់ផលិតផលកសិកម្មរុក្ខាប្រមាញ់និងនេសាទការពារធនធានពន្ធុចំណេះដឹងប្រពៃណីវប្បធម៌ដែលជាសមាសធាតុក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ជំរុញការកសាងកេរ្តិ៍ឈ្មោះម៉ាកផលិតផលរបស់ព្រះរាជាណាចក្រកម្ពុជា ជំរុញកំណើនទេសចរណ៍ អភិវឌ្ឍផលិតផល បច្ចេកវិទ្យា អនុវត្តច្បាប់ពាក់ព័ន្ធកម្មសិទ្ធិបញ្ញា ចូលរួមលើកកម្ពស់ជីវភាពប្រជាពលរដ្ឋនិងសេដ្ឋកិច្ច សង្គម។

*ដោយ ផាត់ លេង (ក.ស.វ. - ក្រុម ២)*

# III- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំឆមាសទី១ ឆ្នាំ២០២៣*



ការវិភាគនេះ ត្រូវបានរៀបចំឡើងក្រោយកិច្ចប្រជុំនៃក្រុមការងារបច្ចេកទេស នៃក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌(ក.ស.វ) ដើម្បីពិភាក្សាលើស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលបានប្រព្រឹត្តទៅនាថ្ងៃអង្គារ ១៤រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ក្រោមអធិបតីភាព ឯកឧត្តម **នរ៉ាណារិទ្ធិ អានន្ទយ៉ាត** អនុប្រធានក.ស.វ និងជាប្រធានទទួលបន្ទុកក្រុម២ ឯកឧត្តម ប្រធានក្រុមការងារបច្ចេកទេស ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាសមាជិកក្រុមការងារប្រឹក្សាយោបល់ និងក្រុមការងារបច្ចេកទេសរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌ តាមរយៈប្រព័ន្ធហ្ស៊ូម។ ការវិភាគនេះផ្អែកលើទិន្នន័យព័ត៌មាន ដែលទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➡ បើប្រៀបធៀបឆមាសទី១ឆ្នាំ២០២៣ ទៅនឹងឆមាសទី១ឆ្នាំ២០២២ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង១,២% ដែលអាចចាត់ទុកថាស្ថិតនៅក្នុងកម្រិតដែលចែងក្នុងគោលនយោបាយ (មិនលើស៥%)។

តារាង១.១- បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តាមខែពីឆ្នាំ២០២១ដល់ឆ្នាំ២០២៣

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា P | សីហា P | កញ្ញា P | តុលា P | វិច្ឆិកា P | ធ្នូ P | ប្រចាំឆ្នាំ P |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០២៣ | ខែដូចគ្នាឆ្នាំមុន | ៣,០% | ២,២% | ០,៧% | ១,១% | ០,៥% | ០,១% | ១,៨% | ២,៦% | ៣,៣% | ៣,២% | ២,៦% | ៣,០% | **២,០%** |
| ២០២២ | ខែដូចគ្នាឆ្នាំមុន | ៤,១% | ៦,៣% | ៧,២% | ៧,៣% | ៧,២% | ៧,៨% | ៥,៤% | ៤,៩% | ៤,៤% | ៣,៦% | ៣,២% | ២,៩% | ៥,៣% |
| ២០២១ | ខែដូចគ្នាឆ្នាំមុន | ២,៦% | ១,៧% | ២,១% | ២,៧% | ៣,០% | ២,៧% | ៣,៣% | ៣,៤% | ៣,០% | ២,៩% | ៣,៨% | ៣,៧% | ២,៩% |

P:តួលេខខែទាំងឡាយនៃឆមាសទី២ និងប្រចាំឆ្នាំ២០២៣ ជាតួលេខព្យាករណ៍(តាមវិធីសាស្ត្របំបែក)

តារាង១.២- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (តាមក្រុមទំនិញ)

| ក្រុមទំនិញ | សន្ទស្សន៍មធ្យម ឆមាសទី១ ឆ្នាំ២០២៣ | សន្ទស្សន៍មធ្យម ឆមាសទី១ ឆ្នាំ២០២២ | អត្រាអតិផរណា នៃក្រុមទំនិញ |
|---|---|---|---|
| ទំនិញប្រើប្រាស់ (២៥៩ មុខ) | ២០០,៥% | ១៩៨,០% | ១,២% |
| ម្ហូបអាហារ | ២៥២,៦% | ២៤៦,០% | ២,៧% |
| ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ១៨១,៤% | ១៧៨,៩% | ១,៤% |
| សម្លៀកបំពាក់និងស្បែកជើង | ១៧៨,៦% | ១៧៤,៣% | ២,៥% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត | ១៤០,០% | ១៤១,៥% | -១,១% |
| គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ | ១៦២,៣% | ១៦០,៣% | ១,២% |
| សុខាភិបាល | ១៤២,៦% | ១៤២,៧% | -០,០២% |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរនិងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

| ក្រុមទំនិញ | សន្ទស្សន៍មធ្យម ឆមាសទី១ ឆ្នាំ២០២៣ | សន្ទស្សន៍មធ្យម ឆមាសទី១ ឆ្នាំ២០២២ | អត្រាអតិផរណា នៃក្រុមទំនិញ |
|---|---|---|---|
| ការដឹកជញ្ជូន | ១២៦,៤% | ១៣២,៣% | -៤,៥% |
| ក្នុងនោះ ប្រេងសាំង | ១០៩,៣% | ១២៥,៧% | -១៣,0% |
| ទូរគមនាគមន៍ | ៦៦,៥% | ៦៦,៦% | -0,២% |
| ការកម្សាន្តនិងវប្បធម៌ | ១៣០,៨% | ១២៧,៦% | ២,៥% |
| ការសិក្សា | ១៧០,៩% | ១៦៨,៥% | ១,៤% |
| ភោជនីយដ្ឋាន | ៣២៣,៨% | ៣២០,៦% | ១,0% |
| ទំនិញនិងសេវាកម្មផ្សេងៗ | ១៦៩,៦% | ១៦៧,២% | ១,៤% |

កំណត់សម្គាល់ : គ្រាគោលគឺត្រីមាសទី៤ ឆ្នាំ២០០៦ = ១០០%

➢ មុខទំនិញដែលឡើងថ្លៃខ្ពស់គឺម្ហូបអាហារ ២,៧%

➡**អត្រាប្តូរប្រាក់** : ជារួមអត្រាប្តូរប្រាក់មានស្ថិរភាព។ ប្រាក់រៀលមានការធ្លាក់ថ្លៃធៀបនឹងប្រាក់ដុល្លារ។

| ប្រភេទ | ចុងឆមាសទី១/២០២៣ | ចុងឆមាសទី១/២០២២ | បម្រែបម្រួល |
|---|---|---|---|
| **៛/១ដុល្លារ** | ៤ ១៣០៛ | ៤ ០៧០៛ | ១,៥% |
| **៛/១បាត** | ១១៦៛ | ១១៦៛ | 0,0% |
| **៛/១ដុង** | 0,១៧៥៛ | 0,១៧៥៛ | 0,0% |

## ២. ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិក្នុងឆមាសទី១ ឆ្នាំ២០២៣ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

➢ចំណូលអនុវត្តបានចំនួន១៤ ៥៦០,៣ប៊ីលានរៀល គិតជាដុល្លារអាមេរិកមានចំនួន៣ ៦៤០,១លានដុល្លារ ស្មើនឹង៥២,0% នៃផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងនោះ ចំណូលចរន្តមានចំនួន ១៣ ០៥៧,៨ ប៊ីលានរៀល គិតជាដុល្លារអាមេរិក មានចំនួន៣ ២៦៤,៤លានដុល្លារ ស្មើនឹង៥១,១%នៃផែនការ និងចំណូលមូលធនចំនួន១ ៥០២,៥ប៊ីលានរៀល គិតជាដុល្លារអាមេរិកមានចំនួន៣៧៥,៦លានដុល្លារ ស្មើនឹង៥៨,៤%នៃផែនការ។

➢ បើធៀបនឹងឆមាសទី១ដូចគ្នា ចំណូលថវិកាជាតិ កើនឡើង១,២% ដែលក្នុងនោះចំណូលចរន្តកើនឡើង ១,៨% ។

➢ ក្នុងចំណូលចរន្ត: ចំណូលសារពើពន្ធក្នុង៦ខែដើមឆ្នាំនេះអនុវត្តបានចំនួន១២ ៣៣៣,៤ប៊ីលានរៀល គិតជាដុល្លារអាមេរិកមានចំនួន៣ ០៨៣,៤លានដុល្លារ។ បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២ ចំណូលសារពើពន្ធថយចុះ៥,៦% ដែលក្នុងនោះពន្ធនិងអាករគយថយចុះ១១,៧% និងចំណូលពន្ធដារថយចុះ១,២% ធៀបនឹងឆមាសដូចគ្នាឆ្នាំមុន(តាមតួលេខអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករ)។ ចំណែកតាមតួលេខរតនាគារជាតិ ចំណូលសារពើពន្ធមានចំនួន ១១ ៨៤៥,៤ប៊ីលានរៀល គិតជាដុល្លារអាមេរិកមានចំនួន២ ៩៦១,៣លានដុល្លារ ស្មើនឹង៥០,៦% នៃផែនការប្រចាំឆ្នាំ។

ក្រាហ្វ ២.១- សមាសធាតុចំណូលសារពើពន្ធ តាមឆមាស (២០១៧-២០២៣)




## តារាង២.១- សមាសភាពនៃចំណូលចរន្ត

| មុខចំណូល | អនុវត្ត ធៀបផែនការ | %Δធៀបនឹង ឆ.១ឆ្នាំ ២០២២ | **មុខចំណូល** | អនុវត្ត ធៀបផែនការ | %Δធៀបនឹង ឆ.១ឆ្នាំ ២០២២ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ(រតនាគារ)** | ៥០,៦% | −០,៩% | **ចំណូលមិនមែនសារពើពន្ធ** | ៥៦,៦% | +៣៧,៨% |
| ✓ពន្ធនិងអាករគយ(**អ.នាគយនិង រដ្ឋាករ**) | | −១១,៧% | ✓កាស៊ីណូ | ២៩,២% | +២៩៣,៥% |
| | | | ✓អាជ្ញាបណ្ណក្នុងស្រុក | ១០១,២% | កើនគំហុក |
| -ពន្ធគយ (របបនាំចូល) | | −៥,៣% | ✓កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | ២៥,៣% | +១០,៥% |
| -អាករពិសេសលើរបបនាំចូល | | −២៤,៧% | ✓ប្រៃសណីយ៍ និងទូរគមនាគមន៍ | ៧១,៤% | +៧១,១% |
| -អាករលើតម្លៃបន្ថែមរបបនាំចូល | | −៣,០% | ✓ រុក្ខាប្រមាញ់ | ១១,៨% | −៧៤,១% |
| -អាករនាំចេញ | | +១៧,៤% | ✓សម្បទានរ៉ែ | ៣៨,៣% | +១៤,៧% |
| -អាករបន្ថែមលើផលិផលតេលសិលា | | −០,៦% | ✓អាកាសចរណ៍ស៊ីវិល | ៦៣,៥% | +២៨៩,៥% |
| ✓ ចំណូលពន្ធដារ(**អ.នា ពន្ធដារ**) | ៥២,២% | −១,២% | ✓ ផលទុនទេសចរណ៍ | ៨៤,៥% | +៦៨១,០% |
| -ពន្ធលើប្រាក់បៀវត្ស | ៥៥,៣% | +១២,៣% | ✓ ជួលសហគ្រាស សម្ភារៈ | ៤៨,១% | +៥,៩% |
| - ពន្ធលើប្រាក់ចំណូល | ៦៤,៤% | −៦,០% | | | |
| - អាករលើតម្លៃបន្ថែម | ៤៧,០% | +១១,៨% | | | |
| -អាករពិសេស | ៣៧,២% | −១២,៣% | | | |
| -ចំណូលផ្សេងៗ | ៥៩,០% | +៣១,៨% | | | |
| -ថវិកាខេត្ត រាជធានី | ៣៤,៦% | −៧,០% | | | |

➢ចំណាយថវិកាជាតិក្នុងឆមាសទី១ឆ្នាំ២០២៣ អនុវត្តបានចំនួន១១ ០២៧,២ប៊ីលានរៀល គិតជាដុល្លារអាមេរិកមានចំនួន២ ៧៥៦,៨លានដុល្លារ ស្មើនឹង៣៦,២% នៃផែនការប្រចាំឆ្នាំ ក្នុងនោះ ចំណាយចរន្តសម្រេចបានចំនួន៨ ២៥១,៧ប៊ីលានរៀល ស្មើនឹង៣៩,៦%នៃផែនការ និងចំណាយមូលធនមានចំនួន២ ៧៧៥,៦ប៊ីលានរៀលស្មើនឹង២៨,៩%នៃផែនការ។

➢បើប្រៀបធៀបឆមាសទី១ដូចគ្នាឆ្នាំ២០២២ចំណាយថវិកាជាតិកើនឡើង០,៧%ក្នុងនោះចំណាយចរន្តកើនឡើង២,៧% ប៉ុន្តែចំណាយមូលធនថយចុះ៤,៩% ។

➢ថវិកាជាតិនាឆមាសទី១ឆ្នាំ២០២៣ មានអតិរេកចំនួន៣ ៥៣៣,១ប៊ីលានរៀល ស្មើនឹង៨៨៣,៣លានដុល្លារអាមេរិក។

## ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុនាចុងឆមាសទី១ ឆ្នាំ២០២៣មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុ M2 មានចំនួន១៨២ ៤៩២,៨ប៊ីលានរៀលកើនឡើង៩,២%ធៀបនឹងឆមាសទី១ ឆ្នាំ២០២២។

ក្រាហ្វ៣-សមាសធាតុរូបិយវត្ថុ

ចុងឆមាសទី១ឆ្នាំ២០២២




នាចុងឆមាសទី១ឆ្នាំ២០២៣




➢ការកើនឡើងនៃ M2 នេះបណ្តាលមកពីកំណើននៃ រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ៨,0% និងប្រាក់បញ្ញើផ្សេងទៀត១៣,៥%។

➢ប្រាក់រៀលនៅក្នុង និងក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើរមានចំនួន១៧,0% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,0% នៃរូបិយវត្ថុ$M_2$។

➢**ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ** មានចំនួន១៩៨ ៥៤៤,0ប៊ីលានរៀលកើនឡើង១០,១% ធៀបនឹងឆមាសទី១ ឆ្នាំ២០២២។

➢***អត្រាការប្រាក់ប្រចាំឆ្នាំ***

| ប្រភេទអត្រាការប្រាក់ | ចុងឆមាសទី១ ឆ្នាំ២០២៣ | ចុងឆមាសទី១ ឆ្នាំ២០២២ | បម្រែបម្រួល |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៧% | ៥,៨% | ១៥,៤% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៥,៨% | ៤,២% | ៣៨,០% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ៨,៦% | ១១,០% | -២១,៤% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,៥% | ៨,២% | ៣,២% |
| កម្ចីជារៀលនៅអេម្រឹត | ១៧,៩% | ១៧,៦% | ២,០% |
| កម្ចីជារៀលនៅអិល អូ អិល ស៊ី | ១៨,០% | ១៧,២% | ៤,៧% |
| កម្ចីជារៀលនៅប្រាសាក់ | ១៦,៧% | ១៦,៨% | -០,១% |

## ៤. ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងថាមពល

ក្នុងឆមាសទី១ ឆ្នាំ២០២៣ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម ៖

### ➡កសិកម្ម

➢តារាងខាងក្រោមបង្ហាញផ្ទៃដីដំណាំផ្សេងៗ ឆ្នាំ២០២១ ៦ខែដើមឆ្នាំ២០២២ និង៦ខែដើមឆ្នាំ២០២៣។

| ប្រភេទដំណាំ | ឆមាសទី១-២០២៣ | ឆមាសទី១-២០២២ | ឆ្នាំ២០២១ |
|---|---|---|---|
| ផ្ទៃដីដាំស្រូវវស្សា (ពាន់ហិកតា) | ១ ៩៩៨,៨ | ១ ៤៨៣,២ | ២ ៩០៣,២ |
| ផ្ទៃដីដាំពោត (ពាន់ហិកតា) | ១១៧,៩ | ១០០,៥ | ៧៧,៩ |
| ផ្ទៃដីដាំដំឡូងឈើ (ពាន់ហិកតា) | ៤៩៩,៩ | ៤៩៤,៥ | ៥៤២,០ |
| ផ្ទៃដីដាំដំឡូងជ្វា (ពាន់ហិកតា) | ១,៤ | ១,៤ | ២,១ |
| ផ្ទៃដីដាំបន្លែគ្រប់មុខ (ពាន់ហិកតា) | ២២,០ | ២២,៥ | ២៧,៥ |
| ផ្ទៃដីដាំសណ្តែកបាយ (ពាន់ហិកតា) | ១១,០ | ១០,៨ | ១៣,៣ |
| ផ្ទៃដីដាំសណ្តែកដី (ពាន់ហិកតា) | ៣,០ | ៣,១ | ៥,១ |
| ផ្ទៃដីដាំសណ្តែកសៀង (ពាន់ហិកតា) | ២,១ | ២,៦ | ២,៣ |
| ផ្ទៃដីដាំកៅស៊ូសរុប (ពាន់ហិកតា) | ៤០៤,៦ | ៤០៤,០ | ៤០៤,១ |
| ក្នុងនោះ ផ្ទៃដីចៀរជ័រ | ៣១៥,៣ | ៣១០,២ | ២៩២,៥ |

➢ ផលិតផលនេសាទមានចំនួន៣៧៥,៦**ពាន់តោន**កើនឡើង៨,៣% បើធៀបនឹងឆមាសទី១ដូចគ្នាឆ្នាំ២០២២។

➢ ផលិតផលកៅស៊ូមានចំនួន១៣៨,៨ពាន់តោន កើនឡើង ៣,០% ធៀបនឹងឆមាសទី១ដូចគ្នាឆ្នាំ២០២២។ ផ្ទៃដីចៀរជ័រមានចំនួន៣១៥,៣ ពាន់ហិកតាកើនឡើង១,៧% ធៀបនឹងឆមាសទី១ដូចគ្នាឆ្នាំ២០២២ និងផ្ទៃដីដាំដុះសរុបមាន ៤០៤,៦ ពាន់ហិចតាកើនឡើង០,១%ធៀបនឹងឆមាសទី១ដូចគ្នាឆ្នាំ២០២២។

### ➡រ៉ែនិងថាមពល

➢ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៨ ១០៩,៥GWh កើនឡើង ១០,០%ធៀបនឹងឆមាសទី១ ឆ្នាំ២០២២។ ក្នុងនោះ(ធៀបនឹងឆមាសទី១ឆ្នាំ២០២២)

- វារីអគ្គិសនីមានចំនួន២ ៤៣៦,១GWh ថយចុះ២៥,៤% ( ស្មើ៣០,០%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)
- អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន៤ ៧១៣,២GWh កើនឡើង១៥៧,៤%(ស្មើ៥៨,១%នៃអគ្គិ-សនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)
- អគ្គិសនីសរុប ផ្គត់ផ្គង់ដោយថាមពលពន្លឺព្រះអាទិត្យ(Solar)មានចំនួន៤០៩,៦GWh កើនឡើង ២០,២%(ស្មើ៥,១% នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)
- អគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន៨៧,៦GWh ថយចុះ៧៤,៩% (ស្មើ១,១%នៃអគ្គិសនីសរុបផ្គត់ផ្គង់ ដោយអគ្គិសនីកម្ពុជា)
- និងអគ្គិសនីនាំចូលពីប្រទេសជិតខាងដោយមានចំនួន៤៦៣,០GWh ថយចុះ៧០,៨% (ស្មើ៥,៧%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)។

➢ផលិតកម្មស៊ីម៉ង់ត៍មានចំនួន ៤ ០៤១,១ពាន់តោនមានការថយចុះ១៣,១%បើធៀបនឹងឆមាសទី ១ ដូចគ្នា ឆ្នាំ២០២២។

**➡ឧស្សាហកម្ម**

**➢ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៥៣៨,៥ លានដុល្លារអាមេរិច មានការថយចុះ៨៨,៦% ធៀបនឹងឆមាសមុន និងថយចុះ ៨៩,៦% ធៀបនឹងឆមាសទី១ដូចគ្នា ឆ្នាំ២០២២។**

➢ ទឹកស្អាតផ្គត់ផ្គង់ដោយរដ្ឋាករទឹកមានចំនួន២១៣,២លានម$^3$ កើនឡើង៩,៧% បើធៀបនឹងឆមាសទី ១ដូចគ្នា ឆ្នាំ២០២២។

➢ឧស្សាហកម្មធុនតូច និងសិប្បកម្មបើកថ្មី និងបន្តនៅក្រសួងឧស្សាហកម្ម៖

| *ប្រភេទ* | *ចំនួន* :ឆមាស១ ឆ្នាំ ២០២៣ | *ចំនួន* :ឆមាស១ ឆ្នាំ ២០២២ | បម្រែបម្រួល |
|---|---|---|---|
| ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១ ៩៩៧ | ១ ៩៣៣ | +៣,៣% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ៥៩៥ | ៦៣១ | -៥,៧% |
| ឧស្សាហកម្មធុនតូច និងសប្បកម្ម (បន្ត) | ៧៤៧ | ៦៨៨ | +៨,៦% |

**➡សំណង់**

➢សំណង់អនុញ្ញាតឱ្យសាងសង់មានចំនួន ៦ ៨១៧, ០ ពាន់ម$^2$ កើនឡើង ១៣៩,២% បើធៀបនឹងឆមាសទី១ ឆ្នាំ២០២២។ ការអនុញ្ញាតនេះជាទឹកប្រាក់មានចំនួន ២ ៧៥៩,៤ លានដុល្លារ កើនឡើង ១២៩,៥%បើធៀបនឹង៦ខែដើមឆ្នាំ២០២២។ ក្នុងនោះប្រភេទសំណង់សំខាន់ៗមាន ៖

| *ប្រភេទសំណង់* | ពាន់ម$^2$ :ឆមាសទី១ ឆ្នាំ ២០២៣ | ពាន់ម$^2$ :ឆមាសទី១ ឆ្នាំ ២០២២ | បម្រែបម្រួល |
|---|---|---|---|
| លំនៅឋាន | ៣ ១៧១,៧ | ១ ៣០៩,៥ | +១៤២,២% |
| ឧស្សាហកម្ម | ១ ៩៤២,៩ | ៧៣២,៥ | +១៦៥,២% |
| ពាណិជ្ជកម្ម | ១ ១០០,៨ | ៥៨៧,៧ | +៨៧,៣% |
| ទេសចរណ៍ | ១៧០,៧ | ១២៤,៩ | +៣៦,៧% |
| ... | | | |
| អនុញ្ញាតសរុប | ៦ ៨១៧,០ | ២ ៨៥០,១ | +១៣៩,២% |

➢ **ដូច្នេះ** ក្នុងការអនុញ្ញាតឆមាសទី១ឆ្នាំនេះ សំណង់ដែលពេញនិយមគឺលំនៅឋាន (៤៦,៥%នៃផ្ទៃក្រឡាសរុប) និងឧស្សាហកម្ម (២៨,៥% នៃផ្ទៃក្រឡាសរុប)។

**➡សេវាកម្ម និងទេសចរណ៍**

➢ការចុះបញ្ជី និងលុបចេញពីបញ្ជី ៖

| *ប្រភេទ* | *ចំនួន* :ឆមាស១ ឆ្នាំ ២០២៣ | *ចំនួន* :ឆមាស១ ឆ្នាំ ២០២២ | បម្រែបម្រួល |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២ ៥០៩ | ២ ៤៥៦ | +២,២% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជី ពាណិជ្ជកម្ម | ៤២៥ | ៣៤៤ | +២៣,៥% |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ៣ ១៣០ | ២ ៩២២ | +៧,១% |

## ➡ការងារ

| ប្រភេទ | ឆមាសទី១ ឆ្នាំ ២០២៣ (នាក់) | ឆមាសទី១ ឆ្នាំ ២០២២ (នាក់) | បម្រែបម្រួល |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារធ្វើ( ទីភ្នាក់ងារមុខរបរនិងការងារ ) | ១១ ១៧២ | ១ ០៨៦ | +៩២៨,៧% |
| អ្នកទទួលការងារធ្វើថ្មីតាមរយៈក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងទីភ្នាក់ងារជ្រើសរើសឯកជន | ១៩៩ ៣៩១ | ១៧៩ ០៨៧ | +១១,៣% |
| អ្នកទទួលបានការងារធ្វើក្នុងប្រទេស | ១៧៣ ៦៥៧ | ១៦៩ ៩៧៥ | +២,២% |
| អ្នកទទួលបានការងារធ្វើក្រៅប្រទេស | ២៥ ៧៣៤ | ៩ ១១២ | +១៨២,៤% |

## ➡វិនិយោគ

➢គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មី និងពង្រីក)

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ ២០២៣ | ឆមាសទី១ ឆ្នាំ ២០២២ | បម្រែបម្រួល |
|---|---|---|---|
| **អនុញ្ញាតសរុប** (លានដុល្លារ) ក្នុងនោះ : | ១ ១០៥,៧ | ២ ៩៩៨,៨ | -៦៣,១% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១៦៣,៥ | ១០៤,៩ | +៥៥,៩% |
| វិស័យឧស្សាហកម្ម | ៨៥៩,៤ | ១ ០៣៧,៨ | -១៧,២% |
| ក្នុងនោះ តំបន់សេដ្ឋកិច្ចពិសេស | ៣០៥,៥ | ៣៦០,៣ | -១៥,២% |
| វិស័យទេសចរណ៍ | ៦៨,៨ | ១២៩,០ | -៤៦,៧% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១៤,០ | ១ ៧២៧,១ | -៩៩,២% |
| **គម្រោងថ្មី និងគម្រោងពង្រីក (ចំនួន)** | ១១៣ | ៩៨ | +១៥,៣% |
| **បង្កើតការងារ (ពាន់នាក់)** | ១២២,០ | ៧២,៣ | +៦៨,៧% |

➡**ទំនិញឆ្លងកាត់តាមកំពង់ផែ** (សរុប២កំពង់ផែ)មានចំនួន ៦ ៧៩១,៦ ពាន់តោនថយចុះ០,៥%ធៀបនឹងឆមាសទី១ ឆ្នាំ២០២២។ ក្នុងនោះ :

| *ប្រភេទ* | ឆមាសទី១ឆ្នាំ២០២៣ (ពាន់តោន) | ឆមាសទី១ឆ្នាំ២០២២ (ពាន់តោន) | បម្រែបម្រួល |
|---|---|---|---|
| កំពង់ផែស្វយ័តភ្នំពេញ | ២ ០១២,៣ | ២ ១០៤,៩ | -៤,៤% |
| កំពង់ផែស្វយ័តក្រុងព្រះសីហនុ | ៤ ៧៧៩,៣ | ៤ ៧២៣,១ | +១,២% |

➢**ការចុះបញ្ជី និងចរាចរណ៍**

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ២០២៣ | ឆមាសទី១ ឆ្នាំ២០២២ | បម្រែបម្រួល |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ១៧៣,០ | ២៧៥,៧ | -៣៧,៣% |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី (ពាន់គ្រឿង) | ៣៧,១ | ៤៦,៦ | -២០,៣% |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍(លើក) | ១ ៥៤៨ | ១ ៥៨៣ | -២,២% |

➡ **អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍**

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ ២០២៣(ពាន់នាក់) | ឆមាសទី១ ឆ្នាំ ២០២២(ពាន់នាក់) | *បម្រែបម្រួល* |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៤៧,៥ | ១១,២ | +៣២៤,៦% |
| ភ្ញៀវទេសចរបរទេសទិញប័ណ្ណទស្សនាអង្គរ | ៣៨៥,៨ | ៦០,០ | +៥៤៣,១% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១០១,៩ | ២៦,០ | +២៩១,៧% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២ ៣៦៥,១ | ៦៤១,៨ | +២៦៨,៥% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ៨៦២,៩ | ១៨១,២ | +៣៧៦,១% |
| ចំនួនទេសចរផ្ទៃក្នុង | ១២ ២៩៣,០ | ៧ ០១៣,៤ | +៧៥,៣% |
| អ្នកទេសចរអន្តរជាតិមកដល់កម្ពុជា | ២ ៥៧៩,៩ | ៥០៦,៦ | +៤០៩,៣% |
| ✓តាមផ្លូវអាកាស | ៩១២,៨ | ២៤០,៦ | +២៧៩,៣% |
| ✓ តាមផ្លូវគោក និងទឹក | ១ ៦៦៧,១ | ២៦៦,១ | +៥២៦,៤% |

➡ **ប្រៃសណីយ៍និងទូរគមនាគមន៍**

| *ប្រភេទ* | *ឆមាសទី១ ឆ្នាំ ២០២៣* | *ឆមាសទី១ ឆ្នាំ ២០២២* | *បម្រែបម្រួល* |
|---|---|---|---|
| បញ្ញើក្នុងប្រទេស | ៦៩,០ | ៨០,៣ | -១៤,០% |
| ក្នុងនោះទទួល | ១៩,០ | ១៨,១ | +៥,០% |
| បញ្ញើក្រៅប្រទេស | ២០៣,៩ | ២០០,៣ | +១,៨% |
| ក្នុងនោះទទួល | ១០៦,៤ | ១៤៦,២ | -២៧,២% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២ ៨៦២,៧ | ៤ ៤១៦,៥ | -៣៥,២% |
| ក្នុងនោះហៅចូល | ១ ០០៩,៥ | ១ ៩៤៩,៨ | -៤៨,២% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៤ ៥៧១,០ | ៧ ៦២២,២ | -៤០,០% |
| ក្នុងនោះហៅចូល | ៤ ៤២១,៧ | ៧ ៤៩៩,២ | -៤១,០% |

## ៥. ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ៖

➡ការនាំចូលក្នុងឆមាសទី១ ឆ្នាំ២០២៣ មានចំនួន៤៧ ៣៤៥,០ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ១១ ៨៣៦,៣លានដុល្លារ ថយចុះ២០,៩%ធៀបនឹងឆមាសទី១ ឆ្នាំ២០២២។ក្នុងនោះមុខទំនិញគួរកត់សម្គាល់មាន៖

| បរិយាយ | %∆ធៀបនឹងឆ.ទី១ ឆ្នាំ ២០២២ | បរិយាយ | %∆ធៀបនឹងឆ.ទី១ ឆ្នាំ ២០២២ |
|---|---|---|---|
| ប្រេងសាំង<br>ប្រេងម៉ាស៊ូត | +១២,១%<br>-៥,៩% | ត្រាក់ទ័រនិងគោយន្ត(ជាគ្រឿង)<br>រថយន្តដឹកជញ្ជូន(ជាគ្រឿង) | -៦៤,៦%<br>-៦៥,២% |
| ឧស្ម័ន | +៧,២% | អង្ករ | +៣៥៩,៧% |
| ប្រេងខ្មៅ | -៩៣,៧% | ផ្លែឈើនិងបន្លែ | +១០៥,២% |
| អគ្គិសនីនាំចូលដោយ EDC | -៧០,៨% | ជីកសិកម្ម | +១៧,៩% |
| ដែកសំណង់ | +២២,១% | ថ្នាំកសិកម្ម | -១៤,៨% |
| ស៊ីម៉ង់ត៍ | -៣៩,១% | | |
| រថយន្តសរុប (ជា ប.ល.រ) | -២៣,១% | | |
| រថយន្តសរុប (ជាគ្រឿង) | -៤០,៣% | | |

➡**ការនាំចេញ** ក្នុងឆមាសទី១ឆ្នាំ២០២៣ មានចំនួន៤១ ៨២៤,៤ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ១០ ២០១,១លានដុល្លារ (មានចំនួន៨៨,៣%នៃការនាំចូល)មានការកើនឡើង១,១%ធៀបនឹងឆមាសទី១ ឆ្នាំ ២០២២។ ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន៖

| *ទំនិញ* | %∆ធៀបនឹងឆ.ទី១ ឆ្នាំ ២០២២ | *ទំនិញ* | %∆ធៀបនឹងឆ.ទី១ ឆ្នាំ ២០២២ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៥១,៥% | ផលិតផលនេសាទ | +៤,៤% |
| វាយនភណ្ឌនិង ស្បែកជើង | -១៧,៦% | កៅស៊ូ | +១១,១% |
| អង្ករ | +០,៩% | | |

# សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ៖ ការប្រកាន់យកប្រព័ន្ធពហុភាគី ដើម្បីលើកកម្ពស់ សន្តិភាព ទាំងក្នុងប្រទេស និងជុំវិញពិភពលោក

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃកម្ពុជា បានដឹកនាំគណៈប្រតិភូទៅបំពេញបេសកកម្មជាផ្លូវការនៅក្រៅប្រទេសជាលើកដំបូង បន្ទាប់ពីឡើងកាន់អំណាច១៥ថ្ងៃ ដើម្បីចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៣ ពីថ្ងៃទី៤-៧ ខែកញ្ញា ឆ្នាំ២០២៣ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ដែលទើបបិទបញ្ចប់ថ្មីៗនេះ។ បើយើងងាកមកផ្តោតលើបញ្ហាភូមិសាស្ត្រនយោបាយនៅក្នុងតំបន់និងអន្តរជាតិ ដែលមហាអំណាចកំពុងប្រកួតប្រជែងគ្នាយ៉ាងក្តៅគគុកនេះ គឺសម្តេចធិបតី បានអះអាងយ៉ាងច្បាស់ៗថា កម្ពុជានៅតែបន្តការប្តេជ្ញាចិត្តចំពោះប្រព័ន្ធពហុភាគី និងសណ្តាប់ធ្នាប់អន្តរជាតិ ដោយផ្អែកលើច្បាប់ និងគោលការណ៍នៃការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង ដើម្បីការពារ និងលើកកម្ពស់សន្តិភាព ទាំងក្នុងប្រទេស និងជុំវិញពិភពលោក ព្រោះក្នុងបរិបទប្រវត្តិសាស្ត្រកម្ពុជា "សន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខ" ដែលគុណតម្លៃទាំងបីនេះ បានប្រែក្លាយព្រះរាជាណាចក្រកម្ពុជា ពីប្រទេសដែលធ្លាប់តែហែកហួរដោយសារសង្គ្រាមទៅជាប្រទេសមួយដែលមានការអភិវឌ្ឍនិងកំណើនសេដ្ឋកិច្ច ៧ ភាគរយក្នុងមួយឆ្នាំ មុនពេលជំងឺកូវីដ-១៩ ដ៏កាចសាហាវរាតត្បាត។ នេះសឱ្យឃើញអំពីសារៈសំខាន់និងភាពខ្លឹមនៃសន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខ គឺជាមូលដ្ឋានគ្រឹះតម្រូវការបឋម និងជាស្នូលនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមសេដ្ឋកិច្ចជាតិដែលមិនអាចខ្វះបានរបស់ប្រជាជាតិនីមួយៗ នៅគ្រប់ប្រទេសទាំងអស់លើពិភពលោក ។

ទន្ទឹមនឹងនេះ ក្នុងវិស័យនយោបាយសេដ្ឋកិច្ច សម្តេចធិបតី ក៏បានជំរុញឱ្យប្លុកអាស៊ាន ខិតខំប្រឹងប្រែងរួមគ្នាដោយរលូន ដើម្បីធានាឱ្យបាននូវការសន្និដ្ឋានទាន់ពេលវេលានិងវិជ្ជមាន ក្នុងការធ្វើឱ្យប្រសើរឡើងនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានឱ្យកាន់តែប្រសើរបន្ថែមទៀត។ ក្នុងនោះសម្រាប់កម្ពុជាចំពោះកម្មវិធីរាជរដ្ឋាភិបាលថ្មី របស់សម្តេចធិបតី នៅអាណត្តិទី៧នេះគឺជាយុទ្ធសាស្ត្របញ្ចកោណដែលជាផែនទីបង្ហាញផ្លូវប្រកបដោយចក្ខុវិស័យដ៏មោះមុតនិងអនុវត្តឱ្យបាននូវផែនការអភិវឌ្ឍឱ្យមានប្រសិទ្ធភាពក្នុងការពន្លឿនការអភិវឌ្ឍន៍ជាតិរបស់សម្តេចធិបតីក្នុងក្តីសុបិន្តនិងជាក្តីស្រមៃ២៥ឆ្នាំខាងមុខ។

ក្នុងការនាំនាវាកម្ពុជាឱ្យដល់គោលដៅប្រកបដោយភាពជឿជាក់និងច្បាស់លាស់ ដែលយើងទាំងអស់គ្នាត្រូវរួមដំណើរជាមួយសម្តេចធិបតី ដើម្បីប្រែក្លាយប្រទេសជាតិរបស់យើងឱ្យក្លាយជាប្រទេសមួយដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ដើម្បីទុកជាមរតកដ៏ប្រពៃថ្លៃថ្លាដល់ប្រជាជាតិនិងកូនចៅយើងបានរស់នៅក្នុងជីវភាពមួយឱ្យកាន់តែប្រសើរនិងភាពក្សេមក្សាន្តតរៀងទៅ។

ដូច្នេះកម្ពុជានឹងធ្វើការយ៉ាងសកម្ម និងជិតស្និទ្ធជាមួយបណ្តារដ្ឋសមាជិកអាស៊ានទាំងអស់ ទាំងវិស័យឯកជនផងដែរ ដែលជាសមាសធាតុផ្សំរួមគ្នាដើម្បីជំរុញនិងពន្លឿនសេដ្ឋកិច្ចជាតិដែលមានខ្លឹមនិងសារៈសំខាន់គឺ "សន្តិភាព" ជាស្នូលទាំងក្នុងប្រទេស ក្នុងតំបន់ និងពិភពលោក៕

ដោយ វ៉ែន្ន សណ្តាប់

# ការសិក្សាស្រាវជ្រាវសាគរសាស្ត្រ និងធនធានជលផល នៅសមុទ្រកម្ពុជាឆ្នាំ១៩៨៣-១៩៨៦ (ត)



រូបភាព២៤. ផែនទីបង្ហាញពីរបាយកំរិតប្រមូលផ្តុំនៃត្រីខែមករាកុម្ភៈ



រូបភាព២៥. ផែនទីបង្ហាញពីរបាយកំរិតប្រមូលផ្តុំនៃត្រីខែកុម្ភៈមីនា



រូបភាព២៦. ផែនទីបង្ហាញពីរបាយកំរិតប្រមូលផ្តុំនៃត្រីខែមេសាឧសភា



រូបភាព២៧. ផែនទីបង្ហាញពីរបាយកំរិតប្រមូលផ្តុំនៃត្រីខែមិថុនាកក្កដា



រូបភាព២៨. ផែនទីបង្ហាញពីរបាយកំរិតប្រមូលផ្តុំនៃត្រីខែកក្កដាសីហា



រូបភាព២៩. ផែនទីបង្ហាញពីរបាយកំរិតប្រមូលផ្តុំនៃត្រីខែកញ្ញាតុលា

ពណ៌បង្ហាញពីរបាយកំរិតប្រមូលផ្តុំនៃត្រី



### ៥.៣.៤ សមាសភាព និងលក្ខណៈនៃប្រភេទត្រីសេដ្ឋកិច្ចសំខាន់ៗ

**ក្រុមត្រីកន្ទុយរឹង** (Chinchard) ក្រុមត្រីកន្ទុយរឹងនេះ ត្រូវបានរកឃើញថាមាន ៣៣ប្រភេទ តាមរយៈការសង្កេតផលត្រីដែលចាប់បានដោយការអួសអួនពិសោធន៍។ ពពួកត្រីទាំងនេះក្តាប់យកចំនួន១៦% នៃផលត្រីដែលចាប់បានសរុបទាំងអស់ នៅខែធ្នូ ឆ្នាំ១៩៨៥ និង ៤០.៧% នៃផលត្រីចាប់បាននៅខែឧសភា ឆ្នាំ១៩៨៥។

**ត្រីកូនគុំ** (Atule Mate) ជាប្រភេទត្រីដែលរាយប៉ាយជាងគេនៅក្នុងសមុទ្រកម្ពុជា។វាបង្ហាញខ្លួនក្នុងផលត្រីចាប់បាននៅគ្រប់តំន់នេសាទ ហើយសមាសភាពរបស់វានៅក្នុងផលត្រីចាប់បានមានកំរិតខ្ពស់ ចាប់ពីខែឧសភាឆ្នាំ១៩៨៥ (១២.៦%) រហូតដល់ខែតុលា (៧.៣%)។នៅអំឡុងពេលនេះត្រីប្រភេទនេះ ត្រូវបានប្រទះឃើញនៅតាមតំបន់ជំរៅទឹក ៣៥-៦០ម៉ែត្រ តែនៅអំឡុងខែវិច្ឆិកា-មេសា ពួក វាបានផ្លាស់ទីមកតំបន់ ទឹករាក់វិញ។ នៅដំណាក់កាលចុងក្រោយនេះបរិមាណត្រីប្រភេទនេះដែលចាប់បានមានពី ៣.២% នៅខែធ្នូ ឆ្នាំ១៩៨៥ ទៅ ៤.៤% នៅខែមេសាឆ្នាំ១៩៨៦ នៃផលត្រីដែលចាប់បានសរុប។

ជាទូទៅត្រីប្រភេទនេះ មានទំហំ ១០-២៦ សង់ទីម៉ែត្រ នៅអំឡុងខែកក្កដា-សីហា ឆ្នាំ១៩៨៣ ត្រីទំហំ ១៧-២១សង់ទីម៉ែត្រ មានចំនួនលើសលប់ (៧១.១%) នៅអំឡុងខែឧសភា-មិថុនាឆ្នាំ១៩៨៥ ត្រីទំហំ១៦-២០សង់ទីម៉ែត្រមានបរិមាណលើសលប់ (៧៤.៦%) នៅអំឡុងខែកញ្ញា-ធ្នូឆ្នាំ១៩៨៥ ត្រីទំហំ២០-២៣សង់ទីម៉ែត្រមានបរិមាណលើសលប់ (៥១%) ហើយនៅអំឡុងខែកុម្ភៈ-មីនា ឆ្នាំ១៩៨៦ ត្រីដែលចាប់បានមានទំហំតូច ១៣-២០ សង់ទីម៉ែត្រក្តាប់យកបរិមាណប្រហែល៧%នៃផលត្រីដែលចាប់បានសរុប។ ទម្ងន់ត្រីនេះប្រែប្រួលពី ៣០ ទៅ ២៥០ ក្រាម ដែលទម្ងន់មធ្យមប្រែប្រួលពី ៨៦ ទៅ ១១៣ ក្រាម។ ពួកវាពងកូននៅទូទាំងឆ្នាំ តែនៅខែមេសា (ឆ្នាំ១៩៨៦) ត្រីដែលពងកូនមានបរិមាណច្រើនរហូតដល់ ២៦.៦% នៃត្រីមេករពង និងនៅខែឧសភា (ឆ្នាំ១៩៨៥) បរិមាណត្រីពងកូនឡើងដល់ ៥៨.៧% នៃត្រីមេករពង (តារាង៦)។ បរិមាណត្រីមេមានលើសលប់គឺមានតែនៅខែធ្នូ តាមអត្រា ១.៣៨:១.០ (ញី:ឈ្មោល)។ នៅខែឧសភាឆ្នាំ១៩៨៥ អត្រាត្រីឈ្មោលញី គឺ ស្មើគ្នា តែនៅដំណាក់កាលផ្សេងទៀតបរិមាណត្រីឈ្មោលមានច្រើនជាងត្រីមេ តាមអត្រា ១.០:១.១ ទៅ ១.០:១.៤។ ការស៊ីចំណីជាអតិបរិមាត្រូវបានប្រទះឃើញនៅអំឡុងខែកញ្ញា-ធ្នូ ឆ្នាំ១៩៨៥ (តារាង៦)។ កំរិតមធ្យមនៃចំណីបំពេញក្រពះមាន ០.៦ដោយនៅអំឡុងខែកក្កដា-សីហាឆ្នាំ១៩៨៣កំរិតចំណីក្នុងក្រពះមាន ០.២៤ នៅអំឡុងខែឧសភា មិថុនា ឆ្នាំ១៩៨៥ មាន ០.៨៣ នៅអំឡុងខែកុម្ភៈ មេសា ឆ្នាំ១៩៨ មាន ០.៥៤ ឯ សមាសភាពចំណីក្នុងក្រពះ ជាទូទៅគឺត្រី៖ ត្រីស្លឹកឬស្សី (Engraulidae), ត្រីកាកើម (Stolephorus), កូនត្រី និងមឹក។

**តារាង៦. ដំណាក់កាលនៃវ័យបន្តពូជនៃក្រពេញបន្តពូជរបស់ត្រីកូនគុំ (Atule mate)**

| រយៈពេលអង្កេត | ដំណាក់កាលនៃវ័យបន្តពូជនៃក្រពេញបន្តពូជ (%) | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | II | II III | III | III IV | IV | IV V | V | V VI | VI | VI IV | VI II | n |
| កក្កដា-សីហា | ១៨.៧ | ៩.៤ | ២៥.០ | ២១.៩ | ១៥៦ | ៦.២ | - | - | - | - | ៣.១ | ៧៥ |
| កញ្ញា-ធ្នូ | ២៣.៨ | ១៦.៧ | ៤៦.៧ | ៨.២ | ៩.០ | ១.៦ | - | - | - | - | - | - |
| កុម្ភៈ-មេសា | ៤២.៣ | - | ១១.៩ | - | ៦.៦ | ៣.៦ | ២.៤ | ០.៩ | ២.៤ | ១៩.៥ | ១០.០ | ២១.៦ |
| ឧសភា-មិថុនា | - | - | - | - | - | ៨.៩ | ៩.៦ | - | - | ៤០.២ | - | - |

កំណត់ចំណាំ: II: ក្រពេញបន្តពូជចាប់ផ្តើមរីក; II III: ក្រពេញរីកធំដូចបន្ទាត់ពណ៌លឿងខ្ចី; III: ក្រពេញរីកធំជាងមុនពណ៌ទឹកដោះគោខាប់; III IV: ក្រពេញចេញជាក្រឡាធំៗ; IV: ក្រពេញចេញគ្រប់ពណ៌លឿង; IV V: គ្រាប់ពងនៃក្រពេញឡើងពណ៌ប្រផេះ; V: គ្រាប់ពងនៃក្រពេញឡើងពណ៌ខ្មៅ, V VI: គ្រាប់ពងនៃក្រពេញចេញអុចខ្មៅ; VI: ទម្លាក់ពងលើកទី១ប្រហែល៣០%; VI IV: ទម្លាក់ពងលើកទី២ប្រហែល៣០%; VI II: ពងនៅសល់ហៀរចេញបង្ហើយ; n: ដំណាក់កាលគ្មានពង។

**ត្រីផ្ទួតលឿង** (Selaroides leptolepis) ត្រីប្រភេទនេះត្រូវបានប្រទះឃើញនៅគ្រប់ផលត្រីដែលនេសាទបាន។ ពួកវាក្តាប់យកបរិមាណពី ៦.៨% ទៅ ១២.៧% នៃផលត្រីចាប់បាននៅអំឡុងខែកក្កដា-កញ្ញា ដែលមានបរិមាណមធ្យម ១៦០គក្រ/ម៉ោង នៃការអូសអួនពិសោធន៍។ នៅអំឡុងខែវិច្ឆិកា-ធ្នូ ត្រីនេះក្តាប់យកពី ១.៨% ទៅ ៣.២% នៃផលត្រីចាប់បានជាសរុបដែលគិតជាមធ្យមមានចំនួន ៥០គក្រ/ម៉ោង នៃការអូសអួននេសាទពិសោធន៍។ភាពញឹកញាប់នៃការបង្ហាញមុខរបស់ពួកវាមាន ៦៨% នៅអំឡុងខែវិច្ឆិកា-ធ្នូ និង៥៧% នៅអំឡុងខែកក្កដា-កញ្ញា។ ត្រីដែលចាប់បាននៅខែកក្កដា ឆ្នាំ១៩៨៣ មានទំហំ ៨-១៤សម ដែលគិតជាមធ្យម ១០.៨សម ដែលនៅខែឧសភា-កក្កដាឆ្នាំ១៩៨៥ មានទំហំ ៤-១៧សម (ទំហំមធ្យម១០.៩៣សម) នៅអំឡុងខែកញ្ញា-ធ្នូ ឆ្នាំ១៩៨៥ មានទំហំ ៧-១៣សម (ទំហំមធ្យម ១០.០២សម) នៅអំឡុងខែកុម្ភៈ-មេសា ឆ្នាំ១៩៨៦ មានទំហំ ៦-១៦សម (ទំហំមធ្យម១១.៧៥សម)។

ទំហំត្រីដែលមានច្រើនលើសលប់នៅអំឡុងខែកក្កដា-កញ្ញា គឺ៩-១២សម និង១១-១៣សម នៅអំឡុងខែកុម្ភៈ-មេសា (៦៨%)។ ទម្ងន់ត្រីប្រែប្រួលពី៦ទៅ៧០ក្រ (ទម្ងន់មធ្យមប្រែប្រួលពី ២១ ទៅ ២៤.៨ក្រ)។ ត្រីពងកូនច្រើននៅអំឡុងខែកុម្ភៈ-មេសា ឆ្នាំ១៩៨៦ ដែលមានត្រីមេ ករពងមានរហូតដល់ ៥៨.៤% ក្នុងនោះត្រីទម្លាក់ពងរួចមាន២៤.៣%។ នៅខែកក្កដាឆ្នាំ១៩៨៣ ត្រីមេករពង មានចំនួន៤% (ត្រីមេទម្លាក់ពងរួចមាន១៤%) និងនៅអំឡុងខែឧសភា-មិថុនាឆ្នាំ១៩៨៥ មានចំនួន៤.៣%។ ដោយឡែកនៅអំឡុងខែកញ្ញា-ធ្នូ ឆ្នាំ១៩៨៥ ក្រពេញបន្តពូជត្រីប្រភេទនេះ ទើបតែចាប់ផ្តើមវិវត្តពីកំរិតដំបូង (តារាង៧)។អត្រាភេទឈ្មោលញីមានជិតមួយឯកត្តានៅទូទាំងឆ្នាំ។ ប្រពលភាពនៃការស៊ីចំណីនៅទូទាំងឆ្នាំមិនមានអ្វីគួរឲ្យចាប់អារម្មណ៍ឡើយដោយសារតែកំរិតចំណីបំពេញក្រពះជាមធ្យមចាប់ផ្តើមប្រែប្រួលពី ០.៧៦ ទៅ០.៩។

**តារាង៧. ដំណាក់កាលនៃវ័យបន្តពូជនៃក្រពេញបន្តពូជរបស់ត្រីផ្ទួតលឿង (Selaroides leptolepis)**

| រយៈពេលអង្កេត | ដំណាក់កាលនៃវ័យបន្តពូជនៃក្រពេញបន្តពូជ (%) | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | II | II III | III | III IV | IV | IV V | V | V VI | VI | VI IV | VI II | n |
| កក្កដា-សីហា | ៧៤ | - | - | - | ៨ | ៤ | - | - | - | ១៤ | - | - |
| កុម្ភៈ -មេសា | ៣.៣ | - | ៨.៣ | - | ៧.៧ | ២០.៥ | ៤.៤ | ២៤.៣ | - | ៣១.៥ | - | ១៨ |
| ឧសភា-មិថុនា | ១៦.៥ | - | ៥៦.២ | - | ២៥.៦ | - | - | - | - | ៤.៣ | - | - |

កំណត់ចំណាំ: II: ក្រពេញបន្តពូជចាប់ផ្តើមរីក; II III: ក្រពេញរីកធំដូចបន្ទាត់ពណ៌លឿងខ្ចី; III: ក្រពេញរីកធំជាងមុនពណ៌ទឹកដោះគោខាប់; III IV: ក្រពេញចេញជាក្រឡាធំៗ; IV: ក្រពេញចេញគ្រប់ពណ៌លឿង; IV V: គ្រាប់ពងនៃក្រពេញឡើងពណ៌ប្រផេះ; V: គ្រាប់ពងនៃក្រពេញឡើងពណ៌ខ្មៅ, V VI: គ្រាប់ពងនៃក្រពេញចេញអុចខ្មៅ; VI: ទម្លាក់ពងលើកទី១ប្រហែល៣០%; VI IV: ទម្លាក់ពងលើកទី២ប្រហែល៣០%; VI II: ពងនៅសល់ហៀរចេញបង្ហើយ; n: ដំណាក់កាលគ្មានពង។

**ត្រីកន្ទុយរឹង** (Megalaspis cordyla) ការបង្ហាញខ្លួនច្រើនរបស់ត្រីប្រភេទនេះ នៅក្នុងផលត្រីដែលនេសាទបានដោយការអូសអួនពិសោធន៍ គឺនៅចាប់ពីខែកញ្ញាឆ្នាំ១៩៨៥(៤.៩%នៃផលត្រីចាប់បានសរុប)ដល់ខែមេសាឆ្នាំ១៩៨៦(៣.១%)ដែលផលនេសាទមធ្យមប្រែប្រួលពី ៦០ ទៅ ១៤០គក្រ/ម៉ោង នៃការអូសអួនពិសោធន៍។នៅអំឡុងខែកក្កដា-កញ្ញា ការបង្ហាញខ្លួនរបស់ពួកវាមានតិចតួច ដែលផលនេសាទមានតែ ៣០គក្រ/ម៉ោងនៃនៃការអូសអួនពិសោធន៍ប៉ុណ្ណោះ។ នៅខែឧសភាឆ្នាំ១៩៨៥ ត្រីនេះក្តាប់យក២.២%នៃផលត្រីចាប់បាននិងកាន់តែតិចបំផុត (០.១%) នៅខែកក្កដា ឆ្នាំ១៩៨៣។ នៅខែ

មេសាឆ្នាំ១៩៨៥ត្រីក្នុងវ័យបន្តពូជបានធ្វើបន្លាស់ទីទៅតំបន់ទឹកជ្រៅលើសពី៤០ម៉ែត្រ ឯត្រីវ័យក្មេងរស់នៅតំបន់ទឹករាក់ ព្រោះមិនដែលចាប់បានសោះនៅចន្លោះជំរៅទឹក៣០-៤០ម៉ែត្រ។ភាពញឹកញាប់នៃការបង្ហាញមុខរបស់ត្រីនេះ ត្រូវបានប៉ាន់ស្មានថាមានពី ៥២-៧៣%។

ទំហំត្រីកន្ទុយរឹងប្រែប្រួលទៅតាមរដូវ ដែលនៅអំឡុងខែកក្កដា-សីហា គេច្រើននេសាទបានត្រីប្រវែងពី ១៤ទៅ២១សម ក្នុងនោះទំហំមធ្យមគឺ១០.៥១សម។ទម្ងន់ត្រីប្រែប្រួលពី៥០ទៅ១២០ក្រ ក្នុងនោះទម្ងន់ មធ្យមគឺ ១០៤ក្រ ឯក្រពេញបន្តពូជស្ថិតនៅដំណាក់កាល II នៃការបន្តពូជ ហើយក្រពះគ្មានចំណីសោះ។

នៅអំឡុងខែឧសភាមិថុនា ឆ្នាំ១៩៨៥ ទំហំត្រីប្រែប្រួលពី ២១ ទៅ ៣៦សម ក្នុងនោះគេបានប្រទះ ឃើញក្រុមដែលមានទំហំ២១-២៨សមដូចគ្នា (៧៥%) ដែលគិតជាទំហំមធ្យមគឺ ២៥.៦៦សម។ ទម្ងន់ត្រីប្រែប្រួលពី១០០ទៅ៤៨០ក្រ (ទម្ងន់មធ្យមៈ ២៨៤ក្រ)។ មិនប្រទះឃើញត្រីករពងទេនៅដំណាក់កាលនេះ ឯចំណីក្នុងក្រពះមានកំរិត ១.៣៩ (ពេញណែន) ពោរពេញទៅដោយកូនត្រី។

នៅអំឡុងខែកញ្ញា-ធ្នូ ឆ្នាំ១៩៨៥ ទំហំត្រីប្រែប្រួលពី ១៤ ទៅ ២៨សម ដែលមានទំហំមធ្យមៈ ២១.៣៦ សម)។ គេប្រទះឃើញ១៤%នៃត្រីមេទើបទម្លាក់ពងរួច។ អត្រាភេទត្រី ញីឈ្មោល គឺស្មើគ្នា ឯកំរិតចំណីនៅក្នុងក្រពះ ត្រូវបានប៉ាន់ស្មានថាមាន ១.៨ (ពេញណែនខ្លាំង)។

នៅអំឡុងខែកុម្ភៈ-មេសា ឆ្នាំ១៩៨៦ ទំហំត្រីប្រែប្រួលពី១៩ទៅ២៨សម (ទំហំមធ្យមៈ ២៣.៤៧ សម)។ ទម្ងន់ត្រីប្រែប្រួលពី៦០ទៅ៤០០ក្រ (ទម្ងន់មធ្យមៈ១៤៧ក្រ)។ ត្រីមេចំនួន៥៦.៤% ស្ថិតក្នុងដំណាក់កាលពងកូន និង២៤.៣%ទើបទម្លាក់ពងរួច (តារាង៨)។អត្រាភេទត្រីឈ្មោល/ញីគឺ១.៣:១.០។ ត្រីចំនួន ៤៨៨% មិនមាន ចំណីក្នុងពោះទេ តែកំរិតចំណីជាមធ្យមក្នុងក្រពះនៃត្រីក្រៅពីនោះគឺ ០.៩៨ ពោរពេញទៅដោយត្រី និងមឹក។

**តារាង៨. ដំណាក់កាលនៃវ័យបន្តពូជនៃក្រពេញបន្តពូជរបស់ត្រីកន្ទុយរឹង (Megalaspis cordyla)**

| រយៈពេលអង្កេត | ដំណាក់កាលនៃវ័យបន្តពូជនៃក្រពេញបន្តពូជ (%) | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | II | II III | III | III IV | IV | IV V | V | V VI | VI | VI IV | VI II | n |
| កក្កដា-សីហា | ៥៦.១ | ៥.៧ | ៣៦.៦ | ១.៦ | -- | - | - | - | - | - | - | - |
| កុម្ភៈ-មេសា | ៣០.៧ | ១៥.៨ | - | - | ៥.២ | ២.៦ | - | ៧.៩ | - | - | ៣៧.៧ | ១១.៤ |
| ឧសភា-មិថុនា | ២២.៤ | - | ៥៣.២ | - | ២៤.៤ | - | - | - | - | - | - | - |

កំណត់ចំណាំ: II: ក្រពេញបន្តពូជចាប់ផ្តើមរីក; II III: ក្រពេញរីកធំដូចបន្ទាព័ណលឿងខ្ចី; III: ក្រពេញរីកធំជាងមុនព័ណទឹកដោះគោខាប់; III IV: ក្រពេញចេញជាក្រឡាធំៗ; IV: ក្រពេញចេញគ្រាប់ព័ណលឿង; IV V: គ្រាប់ពងនៃក្រពេញឡើងព័ណប្រផេះ; V: គ្រាប់ពងនៃក្រពេញឡើងព័ណខ្មៅ, V VI: គ្រាប់ពងនៃក្រពេញចេញអុចខ្មៅ; VI: ទម្លាក់ពងលើកទី១ប្រហែល៣០%; VI IV: ទម្លាក់ពងលើកទី២ប្រហែល៣០%; VI II: ពងនៅសល់ហៀរចេញបង្ហើយ; n: ដំណាក់កាលគ្មានពង។

**ត្រីកន្ទុយរឹងខ្លួនខ្ចី** (Decapterus mariadsi)

ប្រភេទត្រីនេះ ត្រូវបានគេសង្កេតឃើញនៅជំរៅទឹកជ្រៅជាង២៧ម៉ែត្រដោយភាពញឹកញាប់របស់វាមានដល់ ៥០-៦៨% ។ ភាពសម្បូររបស់វានៅក្នុងផលនេសាទលេចឡើងនៅតំបន់ជំរៅទឹក៤០-៥០ម៉ែត្រ។ ទំហំត្រីប្រែប្រួលពី ១១ ទៅ ២៣សម ក្នុងនោះទំហំត្រីដែលមានច្រើនលើសលប់៖នៅអំឡុងខែកក្កដា-សីហា ឆ្នាំ១៩៨៣ គឺ១៤-១៧សម (៧១.២%); នៅអំឡុងឆ្នាំ១៩៨៥-១៩៨៦ គឺ ១៦-២០សម។ ទម្ងន់ប្រែប្រួលពី ២០ទៅ ១៨០ក្រ (ទម្ងន់មធ្យមៈ៥៧.៨ក្រ) នៅអំឡុងឆ្នាំ១៩៨៣ ឯទម្ងន់មធ្យមនៅឆ្នាំ១៩៨៥ គឺ ៨១.១ក្រ។បរិមាណត្រីមេករពងមានចំនួន១៨%នៅ

ឆ្នាំ១៩៨៣ ៦.៥% នៅអំឡុងខែកញ្ញា-ធ្នូ ឆ្នាំ១៩៨៥ ៤០.២% នៅអំឡុងខែកុម្ភៈ-មេសាឆ្នាំ១៩៨៦ (តារាង ៩)។ អត្រាភេទត្រីឈ្មោល/ញី មានដូចតទៅៈ (១.៦៨: ១.០០) នៅឆ្នាំ១៩៨៣ (១.០០:១.៥៨) នៅឆ្នាំ១៩៨៥ (១.២៨:១.០០) នៅឆ្នាំ១៩៨៦។កំរិតចំណីក្នុងក្រពះ មាន ០.៥១ នៅអំឡុងខែកក្កដា-សីហា ឆ្នាំ១៩៨៣ និង ០.៨៩ នៅអំឡុងខែកញ្ញា-វិច្ឆិកាឆ្នាំ១៩៨៥។សមាសភាពចំណីក្នុងក្រពះគឺកូនត្រី និងហ្សូអូប្លង់តុង។

**តារាង៨. ដំណាក់កាលនៃវ័យបន្តពូជនៃក្រពេញបន្តពូជរបស់ត្រីកន្ទុយរឹង (Megalaspis cordyla)**

| **រយៈពេលអង្កេត** | **ដំណាក់កាលនៃវ័យបន្តពូជនៃក្រពេញបន្តពូជ (%)** | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | II | II III | III | III IV | IV | IV V | V | V VI | VI | VI IV | VI II | n |
| កក្កដា-សីហា | ៥.៩ | ១.២ | ១៩.០ | ២១.៤ | ៣៤.៥ | ១៥.៥ | - | ២.៥ | - | - | - | ៨៤ |
| កញ្ញា-ធ្នូ | ២៧.២ | ៧.៦ | ២៧.២ | ៧.៦ | ២៣.៩ | ៦.៥ | - | - | - | - | - | |
| កុម្ភះ-មេសា | ១៥.៦ | - | ៣៧.៧ | - | ៦.៥ | ៦.៥ | - | ៣៣.៧ | - | - | - | ៧៧ |

កំណត់ចំណាំៈ II: ក្រពេញបន្តពូជចាប់ផ្តើមរីក; II III: ក្រពេញរីកធំដូចបន្ទាត់ពណ៌លឿងខ្ចី; III: ក្រពេញរីកធំជាងមុនពណ៌ទឹកដោះគោខាប់; III IV: ក្រពេញចេញជាក្រឡាធំៗ; IV: ក្រពេញចេញគ្រប់ពណ៌លឿង; IV V: គ្រាប់ពងនៃក្រពេញឡើងពណ៌ប្រផេះ; V: គ្រាប់ពងនៃក្រពេញឡើងពណ៌ខ្មៅ, V VI: គ្រាប់ពងនៃក្រពេញចេញអុចខ្មៅ; VI: ទម្លាក់ពងលើកទី១ប្រហែល៣០%; VI IV: ទម្លាក់ពងលើកទី២ប្រហែល៣០%; VI II: ពងនៅសល់ហៀរចេញបង្ហើយ; n: ដំណាក់កាលគ្មានពង។

**ត្រីកន្ទុយរឹងពោះស្រួច** (Alepes kalla) គេប្រទះឃើញត្រីប្រភេទនេះក្នុងផលនេសាទនៅជំរៅទឹកតិចជាង៣០ម៉ែត្រ។ ភាពសម្បូរនៃត្រីនេះ ត្រូវប្រទះឃើញនៅអំឡុងខែតុលា-ធ្នូឆ្នាំ១៩៨៥ នៅភាគខាងត្បូងនៃតំបន់សិក្សា។ក្នុងអំឡុងពេលនេះផលនេសាទដែលចាប់បានមានចំនួន៣-៧គក្រ/ម៉ោងនៃការអូសអួនពិសោធន៍ តែនៅខែកុម្ភៈ បរិមាណផលនេសាទមានតិចតួចបំផុត។ នៅខែកុម្ភៈ ឆ្នាំ១៩៨៦ នៅក្បែរឆកកំពង់សោម ផលត្រីដែលចាប់បានឡើងដល់ ១៥០គក្រ/ម៉ោងនៃការអូសអួនពិសោធន៍(ផលចាប់ជាមធ្យមៈ៨គក្រ)។ការនេសាទពិសោធន៍នៅកន្លែងផ្សេងទៀតបានទទួលផលមិនអាចយកជាការបាន។ ទំហំត្រីកន្ទុយរឹងពោះស្រួច ប្រែប្រួលពី ១០ ទៅ ១៥សម ដែលទំហំមធ្យមនៅខែវិច្ឆិកា-ធ្នូឆ្នាំ១៩៨៥ មានប្រវែង ១២.៧៤សម នៅខែកុម្ភៈ-មេសា ឆ្នាំ ១៩៨៦ មានប្រវែង ១២.២៧សម។ នៅអំឡុងខែតុលា-ធ្នូ ក្រពេញបន្តពូជត្រីនេះស្ថិតនៅដំណាក់កាល II – III នៃការបន្តពូជ ដែលមានតែនៅពាក់កណ្តាលខែធ្នូទេដែលត្រីមេចំនួន៦០%មានក្រពេញបន្តពូជដំណាក់កាល IV។នៅអំឡុងខែកុម្ភៈ-មេសា ឆ្នាំ១៩៨៥ ត្រីមេ ចំនួន៥៤% ស្ថិតក្នុងដំណាក់កាលពងកូន(IV–VI)និងចំនួន៥.៨%ស្ថិតក្នុងដំណាក់កាលក្រោយទម្លាក់ពង។អត្រាភេទត្រីឈ្មោល/ញី គឺ ១.៥: ១.០។ប្រពលភាពស៊ីចំណីគឺធំគួរសមដោយនៅអំឡុងខែវិច្ឆិកា-ធ្នូ ឆ្នាំ ១៩៨៥ កំរិតចំណីក្នុងក្រពះមាន១.០ -១.៧ ដែលមានសមាសភាពជា សិលាកំទិចកំណរ (detritus), ហ្វីតូប្លង់តុង និងសត្វសំបករឹងតូចៗ (opepod) ដូចជាប្លង់តុង ឬសត្វតូចៗ រស់នៅស្រទាប់បាត (benthos) ជាសំខាន់។ នៅអំឡុងខែកុម្ភៈមេសាឆ្នាំ១៩៨៦ កំរិតចំណីជាមធ្យមក្នុងក្រពះមានដល់១៦ ដែលសមាសភាព ជាកូនត្រី និងកូនត្រីម្សៅ។

**ត្រីចិនចាស់ខ្មៅ** (Alectis indicus) នៅខែកុម្ភៈឆ្នាំ១៩៨៦គេប្រទះឃើញត្រីប្រភេទនេះនៅជំរៅទឹកតិចជាង២០ម៉ែត្រ ដែលបរិមាណក្តាប់យក២.៧ % នៃផលនេសាទចាប់បាន។ នៅខែមេសា ពួកវាធ្វើបន្លាស់ទីទៅតំបន់ជំរៅទឹក២០-២៧ម៉ែត្រ ដែលបរិមាណផលត្រីចាប់បានមានចំនួន ១៤គក្រ/ម៉ោងនៃការអូសអួនពិសោធន៍។ នៅក្នុងអំឡុងខែកក្កដា-កញ្ញា ឆ្នាំ១៩៨៥ ការនេសាទតំបន់ជំរៅទឹក៣៥ម៉ែត្រ

បានប្រទះឃើញត្រីនេះមានចំនួន១.៤% នៃផលត្រីចាប់បានជាសារុប ដែលផលត្រីចាប់បានជាមធ្យមមាន ១០គក្រ/ម៉ោងនៃការអូសអួនពិសោធន៍។ ទំហំត្រីនេះប្រែប្រួលពី ២០ទៅ១០៤សម។ ក្រុមត្រីទំហំ ៦៣-៨៥សម មានទម្ងន់ ៣.១ ទៅ៨.៥គក្រ (ទម្ងន់មធ្យមៈ១.៧គក្រ) ។ នៅក្នុងអំឡុងខែកក្កដា-កញ្ញា ក្រពេញបន្តពូជវិវត្តដល់ដំណាក់កាល៲៲ នៃវ័យបន្តពូជ។នៅអំឡុងខែកុម្ភៈ-មេសាឆ្នាំ១៩៨៦ត្រីមេករពងមានច្រើនលើសលប់។ចំណីដែលដៅទុកគឺសរីរាង្គជាសត្វល្អិតនៅស្រទាប់បាត និងក្តាមតូចៗ ជាសំខាន់។

**ត្រីកាឡាំងអុចពីរ** (Scomberoidea lysan) នៅអំឡុងខែសីហា-កញ្ញាឆ្នាំ១៩៨៥ ត្រីនេះត្រូវបានប្រទះឃើញនៅជំរៅទឹក៣០ម៉ែត្រ ក្នុងបរិមាណ ១% នៃផលត្រីចាប់បានជាមធ្យមចំនួន៨គក្រ/ម៉ោងនៃការអូសអួនពិសោធន៍។នៅខែកុម្ភៈឆ្នាំ១៩៨៦ត្រីនេះត្រូវចាប់បាននៅជំរៅទឹកតិចជាង២០ម៉ែត្រ ក្នុងបរិមាណ ២.៣%នៃផលត្រីចាប់បានជាសារុប។ភាពញឹកញាប់នៃការបង្ហាញខ្លួនរបស់វាមាន៥០%ឯផលត្រីចាប់បានជាមធ្យមមានចំនួន ១២គក្រ/ម៉ោងនៃការអូសអួនពិសោធន៍។ នៅខែមេសា ត្រីនេះធ្វើបន្លាស់ទីទៅតំបន់ជំរៅទឹក២០-២៦ម៉ែត្រ ជាកន្លែងដែលផលត្រីចាប់បានជាមធ្យមមានចំនួន១៤គក្រ/ម៉ោងនៃការអូសអួនពិសោធន៍ ហើយភាពញឹកញាប់នៃការបង្ហាញខ្លួនរបស់ពួលវាគឺ៧២%។ ទំហំត្រីនេះប្រែប្រួលពី ៣២ ទៅ១២០សម។ ក្រុមត្រីដែលមានទំហំ៦៧-៩០សម មានទម្ងន់ប្រែប្រួលចាប់ពី ២.៧ ទៅ ៩គក្រ (ទម្ងន់មធ្យមៈ៥.៩គក្រ)។ ត្រីនៅដំណាក់កាលធំធាត់ភាគច្រើននៅក្នុងអំឡុងខែសីហា-កញ្ញា ឆ្នាំ១៩៨៥។ នៅអំឡុងខែវិច្ឆិកា-ធ្នូឆ្នាំ១៩៨៥ ត្រីមេដែលវិភាគទាំងអស់ស្ថិតក្នុងដំណាក់កាលពងកូន ដែលនៅក្នុងរយៈកាលនេះ អត្រាត្រីឈ្មោល/ញី គឺស្មើគ្នា។ ប្រពលភាពនៃការស៊ីចំណី មានកំរិតខ្ពស់ ដោយកំរិតចំណីក្នុងក្រពះជាមធ្យមឡើងដល់៣.២ ដែលសុទ្ធតែជាត្រីទាំងអស់។ រាល់ផលនេសាទដែលចាប់បាន គេតែងប្រទះឃើញត្រី២ប្រភេទៈត្រីភ្នែកធំ(Selar boops) ត្រីកន្ទុយរឹងភ្នែកធំ(Selar crumenophthalmus) ដែលទំហំពួកវាប្រែប្រួលពី ១២ ទៅ ២៥សម ដោយក្តាប់យកបរិមាណ០.២% នៃផលត្រីចាប់បានទាំងអស់នៅ ខែកុម្ភៈឆ្នាំ១៩៨៦ ហើយកើនឡើងដល់៥%នៅខែកក្កដាឆ្នាំ១៩៨៣។ដំណាក់កាលពងកូនត្រូវបានសង្កេត ឃើញនៅអំឡុងខែមិនា-ឧសភា ឆ្នាំ១៩៨៦។

**ពពួកត្រីចោរ** (Caranx sp.) ទាំង១២ប្រភេទត្រូវបានរកឃើញក្នុងចំណោមត្រីដែលនេសាទបានៈ ត្រីកាំគួចមាត់វែង(Carangoideschrysophrys)មានទំហំ១២ទៅ៣៥សម ត្រីកាំគួច (Carangoides malabaricus) មានទំហំ១៦-៤៨សម ត្រីកាំគួចខ្ចីមបារាំង (Canrangoides coeruleopinnatus) មានទំហំ ១៥-៣៦សម។ ពេលខ្លះនៅជំរៅទឹក ៣០ម៉ែត្រ គេបានរកឃើញនៅក្នុងផលនេសាទចាប់បាននូវបរិមាណដ៏សម្បូរបែប នៃត្រីកាំគួចព្រុយខ្មៅ (Alepes malanoptera) មានទំហំ១៧-២៤សម ត្រីកាំគួចបង្កា (Alepes djedaba) មានទំហំ១៨-២៦សម។ នៅតំបន់ទឹកជ្រៅ គេនេសាទបានបរិមាណច្រើន តែពពួកត្រីចោរធំៗ (big Caranx sp.) មានចំនួនតិចតួច ដូចជាត្រីកាំគួចព្រុយខៀវ (Caranx melampygus) ត្រីកាំគួចភ្នែកធំ (Caranx sexsfas ciatus) ត្រីកាំគួចខៀវ (Caranx ferdau) ត្រីកាំគួចអុចលឿង (Caranx fulvoguttatus) ដែលមានទំហំ ៤០-៦៧សម និងត្រីកាំគួចទីល (Caranx tille) មានទំហំ៣៦-៤៨សម ដែលប្រទះឃើញនៅតំបន់ទឹកជ្រៅជាអតិបរិមាឯពពួកត្រីកន្ទុយរឹងផ្សេងទៀតត្រូវបានប្រទះឃើញតិចតួចក្នុងបរិមាណដ៏ស្តួចស្តើងបំផុត។

**ត្រីប្លាធូឬកាម៉ុង/ប៉ាឡាំង** (maquereau) ផលត្រីនេសាទបាន មានត្រីកាម៉ុង២ប្រភេទៈ ត្រីប៉ាឡាំង (Rastrellizer kanagurta) និងត្រីប្លាធូ (Rastrellizer brachysoma)។ ពួកវាក្តាប់យកពី ៣៧% ទៅ ១៦២% ក្នុងផលនេសាទសារុបនៅក្នុង

រយៈពេលនៃការនេសាទអួនអូស។ វាអាចជាប្រភេទមួយនៃបណ្ដាប្រភេទ ដែលបញ្ជាក់ពីភាពលើសលប់នៅក្នុងផលនេសាទចាប់បាន។គេមិនសង្កេតការប្រមូលផ្ដុំជាធម្មតាក្នុងបរិមាណសម្បូរបែបឡើយ។ត្រីប៉ាឡាំងត្រូវបានគេសង្កេតឃើញមានបរិមាណធំ ចាប់ពីខែឧសភាឆ្នាំ១៩៨៥ដល់ខែកុម្ភៈឆ្នាំ១៩៨៦។នៅអំឡុងខែកក្កដា-សីហា ដល់ខែកញ្ញា-វិច្ឆិកា ពួកវារស់នៅតំបន់ទឹករាក់ហើយនៅក្នុងអំឡុងខែវិច្ឆិកា-ធ្នូពួកវាធ្វើបន្លាស់ទីទៅតំបន់ទឹកជ្រៅជាង៣៦ម៉ែត្រ។ ភាពញឹកញាប់នៃការបង្ហាញខ្លួនរបស់ពួកវាមាន ពី៨៤% នៅអំឡុងខែមិថុនា-សីហាឆ្នាំ ១៩៨៥ ទៅ ៥៣% នៅខែកុម្ភៈ ឆ្នាំ១៩៨៦។ ផលនេសាទមធ្យមនៅអំឡុងខែមិថុនា-សីហាឆ្នាំ១៩៨៥ មានចំនួន ១៣គក្រ/ម៉ោងនៃការនេសាទអួនអូសពិសោធន៍ ។ នៅអំឡុងខែកញ្ញា-វិច្ឆិកាឆ្នាំ១៩៨៥ មានចំនួន ៩គក្រ/ម៉ោងនៃការនេសាទអួនអូសពិសោធន៍, នៅអំឡុងខែវិច្ឆិកា-ធ្នូឆ្នាំ១៩៨៥មានចំនួន៤គក្រ/ម៉ោងនៃការនេសាទអួនអូសពិសោធន៍។នៅអំឡុងខែមិនា-ឧសភាឆ្នាំ១៩៨៦មានចំនួន៧គក្រ/ម៉ោងនៃការនេសាទដោយអួនអូសពិសោធន៍។ ទំហំត្រីប៉ាឡាំងប្រែប្រួលនៅអំឡុងខែកក្កដា-កញ្ញាពី១៤-២៣សម (ទំហំមធ្យមៈ ១០.៦សម)។ នៅអំឡុងខែកញ្ញា-វិច្ឆិកាពី១២-២២សម (ទំហំមធ្យមៈ១៦.៥៩សម)។ ទម្ងន់ត្រីប៉ាឡាំងប្រែប្រួលពី ៥០-២០០ក្រ (ទម្ងន់មធ្យមៈ៩៧.៤ក្រ និង ១២៦.៦ក្រ)។ នៅអំឡុងខែកក្កដា-កញ្ញាឆ្នាំ១៩៨៥ គេសង្កេតឃើញថា ត្រីដែលមានក្រពេញបន្តពូជដំណាក់កាល II និង III នៃការបន្តពូជមានបរិមាណលើសលប់។ នៅអំឡុងខែកញ្ញា-វិច្ឆិកា ឆ្នាំ១៩៨៥ គេមើលឃើញការកើនឡើងនៃត្រីដែលមានក្រពេញបន្តពូជដំណាក់កាល IV។ នៅអំឡុងខែកុម្ភៈ-មិនា ឆ្នាំ១៩៨៥ ត្រីមេចំនួន ៧២% ស្ថិតក្នុងដំណាក់កាលទម្លាក់ពងកូន និង ៤% នៅខែមេសា ដែលនៅពេលនោះដែរ ត្រីដែលទម្លាក់ពងរួចមានចំនួន ៦៣% (តារាង១០)។ អត្រាភេទត្រីឈ្មោលញីនៅអំឡុងខែកញ្ញា-វិច្ឆិកា ឆ្នាំ ១៩៨៥គឺ ៣.១:១.០។ កំរិតមធ្យមនៃការបំពេញចំណីក្នុងក្រពះនៅអំឡុងខែកក្កដា-កញ្ញាឆ្នាំ១៩៨៥គឺ០.៦៧ និងនៅអំឡុងខែកញ្ញា-វិច្ឆិកា និងអំឡុងខែធ្នូឆ្នាំ១៩៨៥ប្រែប្រួលពី២.០ទៅ២.៦ហើយនៅអំឡុងខែមិនា-ឧសភា ឆ្នាំ១៩៨៦ គឺ ១.៦។ សមាសភាពចំណីមានសិលាកំទិចកំណាហ្វីតូប្លង់តុង និងប៉េរីហ្វាយតុង។

**តារាង១០. ដំណាក់កាលនៃវ័យបន្តពូជនៃក្រពេញបន្តពូជរបស់ត្រីប៉ាឡាំង (Rastrellizer kanagurta)**

| រយៈពេលអង្កេត | ដំណាក់កាលនៃវ័យបន្តពូជនៃក្រពេញបន្តពូជ (%) | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | II | II III | III | III IV | IV | IV V | V | V VI | VI | VI IV | VI II | n |
| កក្កដា-សីហា | ២.៥ | ៥.១ | ៣០.៨ | ១០.៣ | ៧.៨ | ៣៨.៥ | ២.៥ | - | - | - | ២.៥ | ៣៩ |
| កុម្ភៈ-មេសា | ២.៩ | - | ៤.៣ | - | ៤.៧ | ៤.៣ | - | ៥.០ | - | ៥៣.៥ | ១៩.១ | ២៥ |

កំណត់ចំណាំ: II: ក្រពេញបន្តពូជចាប់ផ្ដើមរីក; II III: ក្រពេញរីកធំដូចបន្ទាព់ណលឿងខ្ចី; III: ក្រពេញរីកធំជាងមុនព៌ណទឹកដោះគោខាប់;
III IV: ក្រពេញចេញជាក្រឡាធំៗ; IV: ក្រពេញចេញគ្រប់ព៌ណលឿង; IV V: គ្រាប់ពងនៃក្រពេញឡើងព៌ណប្រផេះ;
V: គ្រាប់ពងនៃក្រពេញឡើងព៌ណខ្មៅ, V VI: គ្រាប់ពងនៃក្រពេញចេញអុចខ្មៅ; VI: ទម្លាក់ពងលើកទី១ប្រហែល៣០%;
V]I IV: ទម្លាក់ពងលើកទី២ប្រហែល៣០%; VI II: ពងនៅសល់ហៀរចេញបង្ហើយ; n: ដំណាក់កាលគ្មានពង។

នៅអំឡុងខែកក្កដា-សីហាឆ្នាំ១៩៨៣និងនៅអំឡុងខែមិនា-មេសាឆ្នាំ១៩៨៦ ត្រីប្លាធូ ឬកាម៉ុង (Rastrellizer brachysoma) ត្រូវនេសាទបានយ៉ាងច្រើន។ នៅអំឡុងខែឧសភាដល់ពាក់កណ្ដាលខែមិថុនា ឆ្នាំ១៩៨៥ ត្រីនេះបានបាត់មុខពីផលនេសាទដែលចាប់បាន តែនៅខែកក្កដា ទើបនេសាទបានត្រីនេះបួនដប់ក្បាល។ នៅភាគខាងជើងនៃតំបន់សេដ្ឋកិច្ចផ្ដាច់មុខកម្ពុជា និងនៅតំបន់ទឹកជ្រៅលើសពី៥០ម៉ែត្រ ទើបគេបានប្រទះឃើញពួចវានៅក្នុងផលនេសាទ។នៅខែកុម្ភៈឆ្នាំ១៩៨៦ ផលត្រីនេះជាមធ្យមមានចំនួន ៣គក្រ/ម៉ោង នៃការនេសាទអួនអូសពិសោធន៍។ នៅអំឡុងខែមេសានៅជំរៅទឹក១៥-២០ម៉ែត្រ ផលនេសាទមធ្យមមានចំនួន ១២៦គក្រ/ម៉ោងនៃការនេសាទអួនអូសពិសោធន៍ និងនៅជំរៅទឹក

២០-៣០មែត្រមានចំនួន៨២គក្រ/ម៉ោងនៃការនេសាទអួនអូសពិសោធន៍ ដែលផលនេសាទជាមធ្យមនៅតំបន់នេះមានចំនួន៩៣គក្រ/ម៉ោងនៃការនេសាទអួនអូសពិសោធន៍។

ត្រីប្លាធូ/កាម៉ុង ដែលចាប់បាននៅអំឡុងខែកក្កដា-សីហាឆ្នាំ១៩៨៣ មានប្រវែងពី១៤ ទៅ ២២សម (ប្រវែងមធ្យម: ១៧.១៦សម) និងនៅអំឡុងខែមិនា-មេសាឆ្នាំ១៩៨៦មានប្រវែងពី១២ទៅ២២សម (ប្រវែងមធ្យម:១៦.៥៩សម)។ទម្ងន់ត្រីនេះប្រែប្រួលពី៣០ទៅ១៨០ក្រ (ទម្ងន់មធ្យម: ១១៤ក្រ)។ នៅអំឡុងខែកក្កដា-សីហាឆ្នាំ១៩៨៣ ត្រីមេចំនួន៤១% មានក្រពេញបន្តពូជរាវ និងត្រីមេចំនួន២.៥% ស្ថិតក្នុង ដំណាក់កាលទម្លាក់ពងកូនរួច។ នៅអំឡុងខែមិនា-ឧសភាឆ្នាំ១៩៨៦ក្រពេញបន្តពូជត្រីមេបានករគ្រាប់ពងនិង២៥.៣%ស្ថិតក្នុងដំណាក់កាលទម្លាក់ពងកូនរួច។អត្រាភេទត្រីឈ្មោល/ញីស្ទើរតែស្មើគ្នា។កំរិតបំពេញចំណីក្នុងក្រពះជាមធ្យមគឺ ១.៥៤ នៅអំឡុងខែកក្កដា-សីហាឆ្នាំ១៩៨៣ និង០.៨៤នៅអំឡុងខែមិនា-ឧសភា ឆ្នាំ១៩៨៦។ សមាសភាពចំណីគឺដូចគ្នានឹងសមាសភាពចំណីនៃត្រីប៉ាឡាំង។

**ត្រីកិ** (Leiognathidae) ត្រីកិស្រស់ (Leiognathus splendens) ជាប្រភេទត្រីដែលក្តាប់យកចំនួន៧៣.២%នៃប្រភេទត្រីកិទាំងអស់ដែលចាប់បាននៅអំឡុងខែកក្កដា-សីហាឆ្នាំ១៩៨៣ ចំនួន៤៤៣% នៅក្នុងអំឡុងខែកក្កដា-កញ្ញា ឆ្នាំ១៩៨៥ និងចំនួន៧២៥% នៅអំឡុងខែកុម្ភៈ-មេសាឆ្នាំ១៩៨៦។ នៅអំឡុងខែកញ្ញាធ្នូ ឆ្នាំ១៩៨៥ ត្រីនេះត្រូវនេសាទបានតិចតួចក្នុងបរិមាណស្តួចស្តើង ដែលមានតែនៅខែធ្នូប៉ុណ្ណោះដែលយើងអាចនេសាទបានច្រើនរហូតដល់២៥០គក្រ/ម៉ោងនៃការនេសាទអួនអូសពិសោធន៍។ ត្រីនេះត្រូវបានប្រទះឃើញនៅតំបន់ជំរៅទឹក១២-៣០មែត្រ ចាប់ពីកោះរុងសន្លឹមរហូតដល់តំបន់សេដ្ឋកិច្ចផ្តាច់មុខនៃប្រទេសវៀតណាម។ផលត្រីកិស្រស់ដែលនេសាទបានមានចំនួន១១០គក្រ/ម៉ោងនៃការនេសាទអួនអូសពិសោធន៍។

ត្រីកិស្រស់ដែលចាប់បានមានប្រវែងពី៦-១១សម (ប្រវែងមធ្យម:៨.៥៣សម) និងប្រវែងពី៥-១២សម នៅឆ្នាំ១៩៨៦ (ប្រវែងមធ្យម:៨.២១សម)។ ទម្ងន់មធ្យមគឺ ២២ក្រ។ ត្រីមេករពងចំនួន៤៨% ត្រូវកត់ត្រាបាននៅឆ្នាំ១៩៨៣ និងចំនួន១៧% នៅឆ្នាំ១៩៨៦ (តារាង១១)។អត្រាត្រីឈ្មោល/ញីគឺ ១.០០:១.២៧និង១.០០:១.៣៦។កំរិតមធ្យមនៃចំណីបំពេញក្រពះឡើងដល់ ១.០៧ និង២.២៨។ ចំណីគោលដៅគឺ សិលាកំទិចកំណរ។

ត្រីកិ១០ប្រភេទទៀត ត្រូវបានប្រទះឃើញគ្រប់កន្លែងពីពេលមួយទៅមួយក្នុងបរិមាណស្តួចស្តើង (តិចជាង ៣គក្រ/ម៉ោង នៃការនេសាទអួនអូសពិសោធន៍)។ប្រភេទដែលសម្បូរក្នុងចំណោមនោះគឺ ត្រីសំបោរ ហៀរគ្មានរំអិល (Gazza minuta) ប្រវែង៦-១៤សម ត្រីកិតូច (Leiognathus bindus) ប្រវែងពី ៦-៩សម ត្រីកិធ្មេញតូច (Secutor insidiator) ប្រវែង ៦-៩សម ត្រីកិវែង (Leiognathus longates) ប្រវែង ៦-១០សម ដែលទំហំពួកវាថយចុះទៅតាមមុខងារនៃជំរៅទឹក។

**តារាង១១. ដំណាក់កាលនៃវ័យបន្តពូជនៃក្រពេញបន្តពូជរបស់ពពួកត្រីកិ (Leiognathidae)**

| រយៈពេលអង្កេត | ដំណាក់កាលនៃវ័យបន្តពូជនៃក្រពេញបន្តពូជ (%) | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | II | II III | III | III IV | IV | IV V | V | V VI | VI | VI IV | VI II | n |
| កក្កដា-សីហា | ២៦.២ | ៤.៨ | ៩.៥ | ១៩.០ | ៣៥៧ | ៥៨ | - | - | ៤.២ | - | - | - |
| កុម្ភៈ-មេសា | ៣២.៦ | - | ២៧.៧ | - | ១៨.៥ | ០.៧ | - | - | ៤.២ | ៧.១ | ៩.២ | ១៤.១ |

កំណត់ចំណាំ: II: ក្រពេញបន្តពូជចាប់ផ្តើមរីក; II III: ក្រពេញរីកធំដូចបន្ទាព៌ណលឿងខ្ចី; III: ក្រពេញរីកធំជាងមុនព៌ណទឹកដោះគោខាប់;
III IV: ក្រពេញចេញជាក្រឡាធំៗ; IV: ក្រពេញចេញគ្រប់ព៌ណលឿង; IV V: គ្រាប់ពងនៃក្រពេញឡើងព៌ណប្រផេះ;
V: គ្រាប់ពងនៃក្រពេញឡើងព៌ណខ្មៅ, V VI: គ្រាប់ពងនៃក្រពេញចេញអុចខ្មៅ; VI: ទម្លាក់ពងលើកទី១ប្រហែល៣០%;
VI IV: ទម្លាក់ពងលើកទី២ប្រហែល៣០%; VI II: ពងនៅសល់ហៀរចេញបង្ហើយ; n: ដំណាក់កាលគ្មានពង។

**ត្រីអាំងកឹយ** ( Lutjanidae ) ត្រីអាំងកឹយក្បាលពក ( Lutjanus sanguineus ) ក្តាប់យកពី ១៧.២% ទៅ ២៧.៧% នៃប្រភេទ ត្រីអាំងកឹយទាំងអស់។ នៅអំឡុងខែមិថុនា-កញ្ញាគេប្រទះឃើញវានៅគ្រប់ជំរៅទឹករហូតដល់ជំរៅ៨០មែត្រ។ នៅអំឡុងខែធ្នូ គេឃើញវានៅទីខ្ពស់ និងតំបន់ជំរៅទឹកជ្រៅជាង ៥០មែត្រ។ ទំហំវាប្រែប្រួលពី ៤០ ទៅ ៨៦សម ហើយទំហំដែលច្រើនលើសលប់គឺ ១៨-២២សម និង ៥៥-៧៤សម។ ទម្ងន់មធ្យមគឺ៨៣០ក្រ ឯកូនត្រីមានទំហំ ២០-២៣សម។ ភាគច្រើននៃត្រី មានក្រពេញបន្តពូជដំណាក់កាល II នៃវ័យបន្តពូជ និងមួយភាគតូច ស្ថិតនៅក្នុងដំណាក់កាល III, IV និងV។ កំរិតមធ្យមនៃចំណីបំពេញក្រពះប្រែប្រួលពី ១.៣៤ នៅឆ្នាំ១៩៨៣ ដល់ ១.៨ នៅឆ្នាំ១៩៨៦។ សមាសភាពចំណីមានត្រីបង្គា និងក្តាម។

ត្រីបោះត្រា (Lutjanus johni) ត្រូវបានប្រទះឃើញតិចតួច នៅជំរៅទឹក៣២មែត្រ ប៉ុន្តែការនេសាទត្រីនេះ ចាប់បានដល់ទៅ ១.៨តោន ក្នុងរយៈពេល៣ម៉ោងនៃការនេសាទអួនអូសពិសោធន៍។ទំហំពួកវាប្រែប្រួលពី ៤០ ទៅ ៨២សម (ទំហំមធ្យមៈ ៦៦.៥សម ដែលជាក្រុមត្រីទំហំ ៦០-៧០សម) )។ ទម្ងន់មធ្យមគឺ ៣.៨គក្រ។ នៅខែកុម្ភៈឆ្នាំ១៩៨៦ ត្រី ១០០% មានប្រពេញបន្តពូជដំណាក់កាល II នៃវ័យបន្តពូជ។នៅខែមិនាគេសង្កេតឃើញត្រីដ៏ច្រើនលើសលប់ស្ថិតក្នុងដំណាក់កាលទម្លាក់ពងកូន។កំរិតមធ្យមនៃចំណីបំពេញ ក្រពះ គឺ ០.៩ ដែលគោលដៅនៃចំណីគឺត្រី។

ត្រីក្រហម (Lutjanus malabaricus) ត្រូវនេសាទបាននៅខែឧសភាឆ្នាំ១៩៨៥ នៅជំរៅទឹកជ្រៅជាង ៥៥មែត្រ ដែលនៅខែមេសា ឆ្នាំ១៩៨៦ គេសង្កេតឃើញថា វាតែនៅទីខ្ពស់ក្រោមទឹកប៉ុណ្ណោះ។ ទំហំត្រីប្រែប្រួលពី២៨-៤៨សមដោយទំហំដែលមានលើសលប់ជាងគេគឺ៣៦-៤៦សម។ទម្ងន់មធ្យមមានដល់ ១០៥០ក្រ។ រាល់ត្រីដែលយកមកវិភាគសុទ្ធតែមានប្រពេញបន្តពូជដំណាក់កាល II នៃវ័យបន្តពូជ។ កំរិតមធ្យមនៃចំណីបំពេញក្រពះឡើងដល់០.៦ដែលសុទ្ធតែជាត្រី។

ត្រីអាំងកឹយឆ្នូតបន្ទះ ( Lutjanus linealatus ) អាចនេសាទបានគ្រប់កន្លែង ក្នុងអំឡុងខែមិថុនា-កញ្ញា ឆ្នាំ១៩៨៥ ដែលនៅអំឡុងខែតុលា-វិច្ឆិកា គេឃើញពួកវាចូលទៅនៅជិតច្រាំង តែនៅខែកុម្ភៈឆ្នាំ១៩៨៦ ពួកវាចុះទៅតំបន់ជំរៅទឹក៣៥-៥០មែត្រ ហើយនៅខែមេសា ពួកវាផ្លាស់ប្តូរកន្លែងទៅរកច្រាំងជាថ្មីទៀត ហើយវាអាចមានទំហំទៅដល់ ៩-១៦សម (ទំហំ មធ្យមៈ១៣.៥សម ដែលនៅក្នុងក្រុមត្រីដែលមានទំហំ១៣-១៥សម)។ ទម្ងន់វាមានពី២០-៧៦ក្រ (ទម្ងន់មធ្យមៈ ៥៥.៥ក្រ)។ ត្រីមេករពងមិនត្រូវបានសង្កេតឃើញឡើយ។កំរិតមធ្យមនៃចំណីបំពេញក្រពះស្មើនឹង១.១ ឯសមាសភាពចំណីគឺ ត្រី និងមឹក។

**ត្រីកាជីអុចខ្នង** (Pomadasyidae) ត្រីកាជីខ្លា (Plectorhinchus pictus) រស់នៅចន្លោះជំរៅទឹក២០-៧៤មែត្រ ក្នុងអំឡុងខែមិថុនា-កញ្ញា និងនៅចន្លោះជំរៅទឹក១២-៣៦មែត្រនៅអំឡុងខែវិច្ឆកា-ធ្នូ។ ទំហំប្រែប្រួលពី២០-៧២សម (ទំហំមធ្យមៈ ៤១.៨៤សម ដែលនៅក្នុងក្រុមត្រីទំហំ ៤៥-៥៥សម)។ នៅអំឡុងខែមិនា-ឧសភាឆ្នាំ១៩៨៦ ត្រីមេចំនួន៤០% ស្ថិតនៅក្នុងដំណាក់កាលទម្លាក់ពងកូន ដែលកាលពីខែកក្កដាឆ្នាំ១៩៨៣ ត្រីមេក្នុងដំណាក់កាលនេះមានចំនួន៤៨% ឯក្រពះត្រីធំៗពេញវ័យទាំងនោះ គ្មានចំណី សោះ។ កំរិតមធ្យមនៃចំណីបំពេញក្រពះរបស់ត្រីតូចៗគឺស្មើនឹង ១.២ ដែលសមាសភាពចំណីរបស់វាគឺ បង្គា។

ត្រីកាជីប្រភេទផ្សេងទៀតដែលចាប់បានៈ ត្រីកាជីអុចខ្នង ( Pomadasys hasta ) ទំហំ១៨-៤២សម ត្រីកាជីជាំខ្នង ( Pomadasys maculatus ) ទំហំ១០-២៣សម ត្រីកាជីកន្ទុយខ្មៅ (Pomadasys guoraka ) ទំហំ៩-១៥សម ត្រូវនេសាទបាននៅជំរៅទឹកតិចជាង៣៤មែត្រ។

**ត្រីក្រហមផ្កាថ្ម** (Priacanthus arenatus) ត្រីក្រហមផ្កាថ្ម (មាន៣ប្រភេទ) ត្រូវនេសាទបាននៅអំឡុងខែធ្នូឆ្នាំ១៩៨៥ក្នុងបរិមាណអតិបរិមាដោយពួកវាក្តាប់យក១២.៤%នៃផលត្រីចាប់បានទាំងអស់ក្នុងដំណាក់កាលស្រង់ទិន្នន័យ។ ត្រីក្រហមភ្នែកលៀន (Priacanthus tayenus) ត្រូវចាប់បាននៅជំរៅទឹក២០-៦០ម៉ែត្រ។ នៅភាគឥសាន្តនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខកម្ពុជាបានបង្ហាញលក្ខណៈពិសេសតាមផលនេសាទអតិបរិមា។ ទំហំត្រីនេះប្រែប្រួលពី ១០-២៦សម (ទំហំមធ្យមៈ ១៦.៩៣សម)។ ទម្ងន់របស់ត្រីនេះប្រែប្រួលពី ២០-២៥០ក្រ (ទម្ងន់មធ្យមៈ ១០០ក្រ)។ នៅខែកញ្ញា ឆ្នាំ១៩៨៥ ត្រីមេចំនួន ៣០.៨% ស្ថិតនៅក្នុងដំណាក់កាលក្រោយទម្លាក់ពងកូនរួច និងត្រីមេចំនួន១.៩% ទៀតកំពុងស្ថិតក្នុងដំណាក់កាលទម្លាក់ពងកូន។កំរិតមធ្យមនៃចំណីបំពេញក្រពះឡើងដល់១.៨ដែលត្រីនិងបង្គាគឺជាសមាសភាពសំខាន់។

**ត្រីកាវ៉ាវ** (Eleutheronema ) ត្រីកាវ៉ាវ ៣ ប្រភេទ ត្រូវនេសាទបាននៅជំរៅទឹក៣០ម៉ែត្រ ដែលប្រភេទសំខាន់មាន៖ ត្រីជំពូកភ្លែកលំអរ (Nemipterus hexodon) មានទំហំពី ១៦-២៥សម និងត្រីជំពូកភ្លែកឆ្នូត (Scolopsis taenioptera) មានទំហំពី ១២-២២សម។នៅជំរៅទឹកពី៣០-៤៧ម៉ែត្រគេបានរកឃើញត្រីអម្បូរនេះចំនួន ១០ប្រភេទ ដែលប្រភេទសំខាន់មាន៖ ត្រីជំពូកភ្លែកសសៃក្រហម (Nemipterus marginatus) មានទំហំពី ១៥-២២សម។ ផលនេសាទជាមធ្យម នៃត្រីកាវ៉ាវសម្រាប់ទូទាំងតំបន់សេដ្ឋកិច្ចផ្តាច់មុខកម្ពុជា នៅអំឡុងខែមិថុនា-កញ្ញា ឆ្នាំ១៩៨៥ មាន៣គក្រ/ម៉ោង នៃការនេសាទអួនអូសពិសោធន៍ និងនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៨៦ មានចំនួន ១១គក្រ/ម៉ោងនៃការនេសាទអួនអូសពិសោធន៍ និងនៅក្នុងខែមេសាឆ្នាំ១៩៨៦ មាន៣គក្រ/ម៉ោង នៃការនេសាទអួនអូសពិសោធន៍។ នៅអំឡុងខែមិនា-មេសាឆ្នាំ១៩៨៦ គេសង្កេតឃើញមានការទម្លាក់ពងកូនយ៉ាងសម្បើមនៃភាគច្រើននៃពពួក ប្រភេទត្រីកាវ៉ាវ (Eleuthreronema) ក្នុងនោះ ត្រីជំពូកភ្លែកពោះលឿង (Nemipterus bathytius) មានទំហំ ពី ១៦ -៣៥សម និងត្រីជំពូកភ្លែកឆ្នូតប្រាំ (Nemipterus tambuloides ) មានទំហំពី ១៧-២៥សម។

**ត្រីគូន** (Clupeidae) ត្រីប្រភេទនេះត្រូវបាននេសាទនៅជំរៅទឹកតិចជាង៤២ម៉ែត្រ។ គេនេសាទបានត្រីគូនឆ្នូតមាស (Sadinellagibbosa) ក្នុងបរិមាណតិចតួច ដែលមានទំហំ ១០-១៤សម នៅជំរៅទឹករហូតដល់៦០ម៉ែត្រ។ ត្រីប្រភេទនេះ គឺជាត្រីដែលបែកខ្ញែកខ្លាំងជាងគេក្នុងចំណោមប្រភេទត្រីគូន។ ប្រភេទត្រីដែលបែកខ្ញែកច្រើន ជាងគេក្នុងចំណោមត្រីទាំង១២ប្រភេទផ្សេងទៀតមាន ត្រីគូនមូល (Dussumieria acuta) ទំហំ១២-១៧សម។ នៅអំឡុងខែមិថុនាកញ្ញាឆ្នាំ១៩៨៥ ផលត្រីគូនជាមធ្យមដែលនេសាទបានរហូតដល់ជំរៅទឹក៤០ម៉ែត្រ មានចំនួន ២៩គក្រ/ម៉ោង នៃការនេសាទអួនអូស និងមានចំនួន ៩គក្រ/ម៉ោងនៃការនេសាទអួនអូស នៅខែកុម្ភៈឆ្នាំ ១៩៨៦ និងមានចំនួន ១៣គក្រ/ម៉ោង នៃការនេសាទអួនអូសនៅខែមេសាឆ្នាំ១៩៨៦។ដំណាក់កាលទម្លាក់ពងកូនដ៏សម្បើមនៃភាគច្រើននៃប្រភេទត្រីគូនគឺនៅអំឡុងខែមិនា-មេសាឆ្នាំ១៩៨៦។

*(នៅមានត)*

ដោយ ទូច ស៊ាងតាណា

## ១- ជ្រុងមួយនៃភាសាខ្មែរ ៖ ចម្ងល់យើងចំពោះពាក្យខ្មែរមាន « រ »

ចម្ងល់យើងបាននិយាយរួចម្តងមកហើយនៃពាក្យខ្មែរមាន«រ»។ ឥលូវនេះយើងសិក្សាសាកល្បងបន្តទៅទៀត នូវពាក្យខ្មែរខ្លះមាន «រ»ដែរ ប៉ុន្តែវាមានសំយោគសញ្ញានៅពីលើពាក្យនោះ ដូចជាពាក្យ: ញ៉័រ ជ័រ ទំព័រ... ពាក្យនេះមិនសូវមានប្រើច្រើនប៉ុន្មានទេ។ យើងសង្កេតឃើញថា ស្នូររបស់ពាក្យ មានសូរស័ព្ទសំលេងខុសពីពាក្យខ្មែរមាន «រ» ខ្លះដែលយើងបានបង្ហាញពីពេលមុន។ពាក្យខាងលើនេះគេនិយមអានពីរបែប ដូចពាក្យកណ្តុរ ខ្នុរ កុរ បង្គុរ...ដែរ។ ស្នូរនៃអំណានពាក្យខាងលើមានដូចតទៅនេះ ៖

ក.អំណានបែបទី១ ៖

ញ៉័រ គេអានថា [ □oa:r ]

ជ័រ - [ coa:r ]

ទំព័រ - [ t□mpoa:r ]

ខ.អំណានបែបទី២ ៖

ញ៉័រ គេអានថា = ញាល់ [ □oal ]

ជ័រ - = ជាល់ [ coal ]

ប៉ុន្តែគេមិនអានថា ទំពាល់ ទេ អាស្រ័យដូចនេះ អ្នកសិក្សាអាចសង្កេតពាក្យខាងលើនេះ ដោយវិភាគសេចក្តីតាមការយល់ថាបែបទាំងពីរនេះណាខុសណាត្រូវ? អំណានណាសមហេតុសមផលជាង។

-អំណានទី១ : យើងពិចារណាថា តើគេអាចលុប«រ»ចោលឬមិនលុប? បើគេលុប«រ» ទៅតើមានវិបត្តិសូរសំលេងដែរឬទេ? បញ្ហានេះ យើងឃើញថា លុប «រ» ចោលពីពាក្យខ្មែរទាំងនេះ គ្មានអ្វីនាំឱ្យខូចស្នូរឬដូរសំលេងខ្មែរទេ។

បើដូចនេះ គេអាចលុបបាន គឺពាក្យទាំងនោះមាន ៖

- សំណេរថា ញ៉ អំណានថា (ញ៉័រ) ដូចដើមដដែល
- សំណេរថា ជ័ អំណានថា (ជ័រ) ដូចដើមដដែល
- សំណេរថា ទំព័ អំណានថា (ទំព័រ) ដូចដើមដដែល

ព្រោះពាក្យនេះមានសំយោគសញ្ញានៅពីលើសម្រាប់សម្គាល់សូរសំលេង មិនឱ្យច្រឡំពាក្យដើម « ញ » សំពត់មាន « ជ » នោះឡើយ។

មតិខ្លះអះអាងថា « រ » ដាក់ពីមុខពាក្យខ្មែរទាំងនោះ សម្គាល់សូរសំលេងញ៉័រនៃសំលេង ដែលស្ទើរសៗនៅខាងចុងពាក្យ។ យើងយល់ថា ពាក្យខ្មែរគ្មានសូររឺសៗដូចពាក្យឥណ្ឌាទេ។ហេតុដូចនេះយើងលុប«រ»ចោលទៅវាស្រួលជាងទុក«រ»ឱ្យនៅស្មុគ្រស្មាញក្នុងភាសាយើង។ ប៉ុន្តែពាក្យខ្លះដែលក្លាយមកពីសំស្ក្រឹត គឺ < -រ- > គេហៅថារបាទ ( ៌ )នោះ ដូចជាពាក្យ ធម៌ ពណ៌ សម្បូណ៌ បរិបូណ៌ នេះជាដើម។ គេពុំអានឱ្យលាន់ឮនូវសូររបាទ ( ៌ )ខាងមុខទេ។ យើងទុកសិទ្ធិសេរីភាពឱ្យពាក្យទាំងនេះឱ្យមានសញ្ញារបាទចុះ ព្រោះជាពាក្យបរទេស។ ប៉ុន្តែយើងរកដំណើរហេតុនៃពាក្យខ្មែរយើងខំដាក់ « រ » នៅខាងចុងពាក្យដែរនោះ តើវាមានប្រយោជន៍អ្វី? លំនាំនេះគឺពិតជាពាក្យខ្មែរយកតាមរបៀបពាក្យបាលីសំស្ក្រឹតនេះខ្លះ ហើយបានជាគេសរសេរពាក្យ ញ៉័រ ជ័រ ទំព័រ មាន« រ » នៅខាងចុងយ៉ាងនេះឯង។

-អំណានទី២:យើងសិក្សាសាកល្បងមើលនូវស្នូរ « រ « អានជា « ល « គឺពាក្យ ញ៉័រ សរសេរតាមអំណានជាញាល់ គឺពាក្យ ជ័រ សរសេរតាមអំណានជាជាល់ ប៉ុន្តែវាដូចនេះ មធ្យោបាយដើម្បីដោះស្រាយបញ្ហា « រ » ពុំអាចរកច្រកចេញរួចឱ្យបានទាំងអស់នោះទេ នៅក្នុងអំណានទី២នេះ។

យើងចង់ដោះស្រាយពាក្យមាន«រ» ឱ្យទៅជា «ល» ទាំងអស់នោះ គឺពិតជាដោះពុំរួច ព្រោះវាទើសនឹងពាក្យពីរព្យាង្គដូចជាពាក្យទំព័រនេះឯង។អាស្រ័យហេតុនេះយើងមានមធ្យោបាយតែមួយគឺលុប«រ»ចោលវាស្រួលជាងគេទាំងអស់។ ដូចនេះការធ្វើវេយ្យាករណ៍ ត្រូវឱ្យស្រប « របកគំហើញ » នៃ «ល្បុប» «រ» នេះឯង។ តែ «ល្បុប» «រ» នេះគឺយើងសិក្សាតែពាក្យខ្មែរសុទ្ធសាធទេ។ ចំណែកឯពាក្យមាន«រ» ទាក់ទង

ភាសាបាលីដូចពាក្យ អន្តរធាន អន្តរជាតិ វរមាតា វរបិតា វរលក្ខណ៍ វរជន វីរបុរស បរលោក បរទេស កម្មករ កសិករ ឧស្សាហាករ ... យើងនឹងលើកយកទៅសិក្សាក្នុងផ្នែកអំណាន និងសំណេរទៀត។

ចម្ងល់យើងចំពោះអំណាន និងសំណេរ ៖

ភាសាខ្មែរយើងក៏ដូចជាភាសាដទៃទៀតដែរ លក្ខណៈជាចាំបាច់នៃភាសាគឺត្រូវមានសូរស័ព្ទវិទ្យា និង រូបស័ព្ទវិទ្យា។ ភាសារបស់ជនជាតិនីមួយៗត្រូវមានលក្ខណៈពីរយ៉ាងនេះ ដោយខានពុំបាន។ កាលណាយើងចង់បង្កើតពាក្យមួយៗ យើងត្រូវយកអក្សរទៅកត់ត្រាចំណាំពាក្យនោះ ហើយយើងអាចបន្លឺនូវពាក្យឱ្យលាន់ឮស្នូរឡើង។ ធម្មតាភាសាតែងកើតនូវសំដីនិយាយជាមុន រួចបានកើតអក្សរជាក្រោយ។ ដូចនេះភាសានិយាយកើតមុន រួចទើបកើតភាសាសរសេរក្រោយ។ ប៉ុន្តែគេឃើញសភាពនៃដំណើររបស់ភាសា មានលក្ខណៈស្របគ្នាក៏មាន ផ្ទុយគ្នាក៏មាន រវាងភាសានិយាយនិងភាសាសរសេរ។

តើភាសាសរសេរមិនគោរពភាសានិយាយឬ?

អាស្រ័យហេតុនេះបានជាគេឃើញអំណាននិងសំណេរម្តងស្របគ្នា ម្តងផ្ទុយគ្នា។ ដោយមានទំនាស់យ៉ាងនេះហើយបានជាយើងឃើញពាក្យអញ្ញត្រស័ព្ទជាច្រើននៅក្នុងភាសានីមួយៗសរសេរយ៉ាងនេះអានយ៉ាងនោះទៅវិញ។ គេពុំអាចធ្វើវេយ្យាករណ៍ឱ្យត្រង់ដូចជាបន្ទាត់បានឡើយ។ លក្ខណៈនេះបង្ហាញថាសំណេរមិនគោរពអំណានមានបញ្ហាស្មុគស្មាញនៅក្នុងភាសានីមួយៗ។ ចំណែកភាសាខ្មែរយើងវិញ មានលក្ខណៈខាងលើនេះពិតប្រាកដមិនអាចប្រកែកបានឡើយ។ គេសង្កេតឃើញភាសានិយាយ និងភាសាសរសេរស្របគ្នាក៏មាន។ យើងទាញលក្ខណៈខ្លះមកបង្ហាញនៅក្នុងភាសាខ្មែរយើងដូចតទៅនេះគឺ ៖

ក.ភាសានិយាយស្របនឹងភាសាសរសេរយើងបានសង្កេតតាមដាននូវភាសាខ្មែរយើងគឺ គេនិយាយថា ៖

- សាច់ សរសេរជា សាច់
- ចាប់ - ចាប់
- ច្បាប់ - ច្បាប់
- កាប់ - កាប់ ...។

ខ.ភាសានិយាយផ្ទុយនឹងភាសាសរសេរ គេនិយាយថា ៖

- សាច់ក្ដី សរសេរជា សេចក្ដី
- ចោមចៅ - ចមចៅ
- អាញ់ - អញ
- ធើ - ធ្វើ
- តូវ - ទៅ
- ឱសុថ - ឱសថ ...។

ល្បើកបង្ហាញខាងលើនេះ ជាឧទាហរណ៍បន្តិចបន្តួចស្តួចស្តើងណាស់ប៉ុន្តែយើងសាកល្បងនូវគំហើញខ្លះទៀត នៅក្នុងអំណាននិងសំណេរ។ នេះមិនមែនជា « របកគំហើញ » ថ្មីទេ គឺជា « ល្បើក =ការលើក » បង្ហាញនូវរបៀបនៃភាសាខ្មែរយើងដែលមានរួចមកហើយ។

១.អំណានគឺជាសំលេងលាន់ឮឡើងសម្រាប់សម្គាល់ស្នូរនៃពាក្យនីមួយៗ។ អំណាននេះមានមកជាមួយភាសានិយាយរួចមកហើយជួនកាលអំណានគេអាចយកមកបង្កើតនៅក្នុងវិធីរៀបចំភាសាក៏មានដែរ ដូចជាវិធីអាននៅក្នុងវេយ្យាករណ៍។ តមកទៀតវេយ្យាករណ៍គឺជាធម៌ភាពរៀបចំភាសាដែលមានមកឱ្យមានរបៀបរៀបរយតាមកំណើតនៃភាសា។ បានសេចក្តីថាវេយ្យាករណ៍កើតក្រោយមានភាសានិយាយនិងកើតដំណាលគ្នាភាសាសរសេរ ឬក្រោយភាសាសរសេរ។មិនតែប៉ុណ្ណោះវិធីអាននិងវិធីសរសេរក៏ត្រូវមាននៅក្នុងវេយ្យាករណ៍នោះដែរ។

២.សំណេរ គឺជាកំណត់សម្គាល់នូវរូបស័ព្ទពាក្យនីមួយៗ វាកើតមកជាមួយនិងភាសា សរសេរ។ ការយកតួព្យញ្ជនៈផ្សំនឹងស្រៈមកកត់ចំណាំពាក្យនោះជាវិធីមួយមានធម៌ភាពតាមដំណើរនៃភាសារបស់ជាតិ។ ក្បួនខ្នាតតម្រៀបតួអក្សរឱ្យទៅតាមសូរស័ព្ទនៃភាសា ក៏ជាក្បួនវេយ្យាករណ៍ដែរ។

ដូចនេះសំណេរប្រព្រឹត្តតាមវេយ្យាករណ៍ ជាក្បួនអក្សរដែលកើតជាភាសាសរសេរនេះឯង។

( នៅមានត )

## ២- ស្វែងយល់ពី កំណើតសីលធម៌

សីលធម៌មានមកតាំងពីមនុស្សយើងចេះគិតពិចារណា (Homo មនុស្ស- Sapien គិតពិចារណា ) គឺតាំងពីចេញពីពួកសត្វព្រីម៉ាត (primate) មកម្លេះ គឺចាប់ពីបីទៅបួនលានឆ្នាំកន្លងមកហើយ ។ កាលនៅជាសត្វនៅឡើយ «សត្វមនុស្ស» មិនទាន់ចេះកំណត់ថាល្អ ថាអាក្រក់នៅឡើយទេ គឺគិតតែប្រខាំគ្នា ដណ្តើមគ្នាស៊ី ។ អ្នកមានកម្លាំងគឺជាអ្នកឈ្នះ ។ លុះ«សត្វមនុស្ស»បានចេះងើបដើរដោយជើងទាំងពីរខាងក្រោយមកខួរក្បាលក៏មានការវិវត្តឈានទៅចេះគិតខុសត្រូវស្គាល់ល្អអាក្រក់ កំណត់បទដ្ឋានរស់នៅបានសមតាមកាលៈទេសៈនៅក្នុងកុលសម្ពន្ធបង្កើតបានក្បួនច្បាប់សីលធម៌(Ethique) សម្រាប់ប្រតិបត្តិ តាម ។ គេអាចប្រដូចសីលធម៌រស់នៅក្នុងពេលនោះ ទៅនឹងក្បួនឬក្រម ឬច្បាប់ល្បែង ។ ឧទាហរណ៍ៈល្បែងចត្រង្គ ល្បែងបាល់ទាត់ ជាដើម។ អ្នកប្រកួត ត្រូវតែគោរពច្បាប់ ដើម្បីឱ្យល្បែងប្រព្រឹត្តទៅបានត្រឹមត្រូវ ។ កុលសម្ពន្ធខ្មែរ ដែលបានមកតាំងទីលំនៅឋាននៅលើទឹកដីកម្ពុជាសព្វថ្ងៃក៏មានសីលធម៌រស់ នៅតាមសម័យកាលនោះដែរ ។

សូមបងប្អូនក្រឡេកមើល បងប្អូនជនជាតិយើង ដែលយើងហៅថា ខ្មែរលើសព្វថ្ងៃ ។ ជនជាតិភាគតិចទាំងនោះ រស់នៅជាកុលសម្ពន្ធដូចជនជាតិខ្មែរដែរ ។ តើកុលសម្ពន្ធនោះ មានសីលធម៌រស់នៅយ៉ាងណា ? ទោះបីជាគេល្ងង់ខ្លៅយ៉ាងណាក៏ដោយក៏គេមានចិត្តទៀងត្រង់មិនភូតកុហក បោកបញ្ឆោតគ្នា។ គេស្រឡាញ់នរណា គេស្រឡាញ់អស់ពីពោះពីពុង ។ គេស្មោះត្រង់នឹងគ្នា គេគោរពចាស់ទុំ ... មិនហ៊ានប្រព្រឹត្តអ្វីមួយឆ្គាំឆ្គងរំលងបទដ្ឋានឡើយ។ផ្ទុយទៅវិញ ប្រសិនបើមាននរណាម្នាក់ប្រព្រឹត្តអំពើអ្វីមួយខុសវិន័យកំណត់នោះ មេកន្ទ្រាញ និងកុលសម្ពន្ធទាំងមូលថ្កោលទោស ព្រមទាំងផ្តន្ទាទោសទៅតាមកំហុស ។ ទង្វើនេះ គឺកុលសម្ពន្ធមានបំណងប្រាថ្នាចង់ឱ្យសមាជិករបស់ខ្លួន រស់នៅត្រឹមត្រូវតាមក្រម-សីលធម៌តែប៉ុណ្ណោះ ។

ការវិវត្តកុលសម្ពន្ធ គឺជាលទ្ធផលនៃឆន្ទៈរួមរបស់មនុស្ស ដែលប្រឆាំងប្រយុទ្ធនឹងធម្មជាតិ ដើម្បីឱ្យខ្លួនចេញផុតពីច្បាប់ព្រៃ ហើយអាចកសាងសង្គមមនុស្សមួយ មានសីលធម៌ មានច្បាប់ទម្លាប់ជាមនុស្សជាតិ ។

កាលមនុស្សលោកមិនទាន់ចេញផុតសម័យបុរេប្រវត្តិ យើងសង្កេតឃើញថា សីលធម៌ដែលបន្តពីជំនាន់មនុស្សមួយ ទៅជំនាន់មនុស្សមួយទៀត ទៅតាមពាក្យសំដីនិយាយតៗគ្នា មិនទាន់មានចារទុក ឬឆ្លាក់លើថ្មជាសម្គាល់នៅឡើយទេ ។លុះមនុស្សបានចេញផុតពីសម័យបុរេប្រវត្តិ កាលពី ៣២០០ឆ្នាំមុន គ.ស គឺដំណាលគ្នានឹងកំណើតអក្សរដែរនោះមនុស្សប្រព្រឹត្តទៅតាមសីលធម៌សាសនា ។ ចិត្តវិទូជំនាន់នោះ បង្វែរចិត្តមនុស្សឱ្យខ្លបខ្លាចអំណាច ឬកម្លាំងធម្មជាតិ មានរន្ទះ ខ្យល់ព្យុះសង្ឃរា ជាដើម ដោយណែនាំឱ្យយល់ដឹងជឿស្លុងថា ធម្មជាតិទាំងមូល គឺអាទិទេពជាអ្នកបង្កើត ។ អាទិទេព មិនគ្រាន់តែបង្កើតមនុស្សប្រុស-ស្រីនៅលើផែនដីនេះទេថែមទាំងបង្កើតទេវតា ដែលចែកជាពីរក្រុម ៖ ក្រុមជួយថែរក្សាជួយចម្រុងចម្រើននិងក្រុមបំផ្លាញកាលណានុស្សមិនគោរពតាមក្រមសីលធម៌ឬមិនបាននឹកនាធ្វើពិធីបូជាផ្សេងៗ ។មិនតែប៉ុណ្ណោះ អាទិទេពបង្កើតទេវតាមួយក្រុមទៀតចាំតែកាត់សេចក្តីរកខុសត្រូវនៅពេលក្រោយមនុស្សធ្វើមរណកាល ។

នៅប្រទេសអេហ្ស៊ីបអំឡុងកាលជាងប្រាំពាន់ឆ្នាំមុនគ.ស.អ្នកដឹកនាំសាសនាបានអប់រំប្រជាជនឱ្យប្រតិបត្តិក្រមសីលធម៌ដោយយកតាមអាទិទេពថាជាអ្នកបង្គាប់ ។គេបានបង្កើតក្រុមចៅក្រម ៤២ អង្គ អមស្តេចយមរាជ ដែលមានឈ្មោះថា អូស៊ីរីស (OSIRIS) ដើម្បីសួរចម្លើយព្រលឹងអ្នកស្លាប់ ។

អាស្រ័យហេតុនេះមនុស្សតែងភ័យខ្លាចហើយខិតខំកសាងខ្លួន ដោយគោរពក្រមសីលធម៌សង្គម និងសាសនា ។

ជារួម នៅគ្រប់សាសនា ផលវិបាកនៃអំពើអកុសលទាំងឡាយ ត្រូវធ្លាក់ទៅលើបុគ្គល ដែលជាអ្នកប្រព្រឹត្ត ហើយត្រូវផ្តន្ទាទោសតាមកំហុសនោះ។

ក្នុងវិស័យនេះតាមការពិតគឺប្រជារាស្ត្រសម័យបុរេ- ប្រវត្តិ ដែលបានកសាងសីលធម៌នេះ រាប់លានឆ្នាំមកហើយ ព្រមទាំងបានកំណត់បទដ្ឋាន(ក្រម) សង្ខេប ដូចតទៅ ៖

- ចូរឯងកុំសម្លាប់គេ កុំប្រទូស្តរ៉ាយនឹងគេ
- កុំលួចទ្រព្យគេ
- កុំបោកបញ្ឆោតគេ កុំមួលបង្កាច់គេ
- កុំប្រព្រឹត្តនូវមេថុនសេវនៈ នឹងស្ត្រីដែលមានគេគ្រប់គ្រង ។

នេះជាបទដ្ឋាន ប្រកបដោយសុភនិច្ឆ័យ (Les règles de bon sens) ដែលមនុស្សជំនាន់ដើមបានកំណត់ ដើម្បីឱ្យសង្គមមនុស្សវិវត្តទៅកាន់វឌ្ឍន-ភាពនិងសុខដុមរមនាជានិរន្តរ៍ ។ ជាការប្រពៃណាស់ដែលសាសនាបានលើកយកក្បួនខ្នាតសីលធម៌នេះជាច្បាប់កើតចេញពីព្រះឱស្ឋព្រះអាទិទេព ។ មិនតែប៉ុណ្ណោះ អ្នកប្រដៅសាសនា បានប្រឌិតរឿងជាច្រើនដែលមានឥទ្ធិពលទៅលើជំនឿរបស់មនុស្ស និងណែនាំអ្នកមានអំណាចឱ្យមករួមសុខ រួមទុក្ខជាមួយប្រជារាស្ត្រ ដោយខ្លាចការវិនិច្ឆ័យនៃព្រះយមរាជ ។

នៅប្រទេសកម្ពុជាយើង ជំនឿសាសនាមានជាហូរហែកន្លងមក មានព្រាហ្មណ៍សាសនា និង ពុទ្ធ-សាសនា ជាដើម ។ សីលធម៌ព្រះពុទ្ធ (morale bouddhique) ក៏មានប្រហាក់ប្រហែលគ្នា នឹងសីលធម៌នៃសាសនាដទៃ។យើងគួរពិចារណាលើពុទ្ធោវាទដែលមានជាង៥០០ឆ្នាំ មុនគ.ស. ។ ថ្វីត្បិតតែសីលធម៌របស់ព្រះពុទ្ធមានមកជាយូរហើយក៏ពិតមែន តែនៅមានតម្លៃអមតៈ សម្រាប់អ្នកកាន់ព្រះពុទ្ធសាសនាប្រតិបត្តិតាមបានគ្រប់ពេលវេលា មិនចំពោះតែអ្នកថ្វាយខ្លួនជាឧបាសកឧបាសិកានោះទេ ។ អ្នកជាបុថុជ្ជន ក៏អនុវត្តបានទាំងអស់ ។ ប្រសិនបើប្រជា-ពលរដ្ឋកម្ពុជាប្រតិបត្តិបានខ្ជាប់ខ្ជួនតាមមាគ៌ាទាំងដប់ គឺ កុសលកម្មបថ ១០ នោះប្រទេសកម្ពុជា មិនបានជួបប្រទះនូវអំពើកាប់សម្លាប់ ព្រាត់ប្រាសយ៉ាងអាណោចអាធ័មដូច្នេះទេ ។

សូមលោកអ្នកគិតជញ្ជឹងមើលថាតើធ្វើដូចម្តេចហ្ន៎ ទើបប្រជារាស្ត្រខ្មែរទាំងមូល ស្ម័គ្រចិត្តទទួលយកសីលធម៌របស់ព្រះពុទ្ធមកប្រតិបត្តិ ។

បន្ទាប់ពីនេះ ស្មេរសូមលើកយកប្រវត្តិព្រះគ្រូខុង ជឺ មកជំរាបជូនដូចតទៅ :

នៅក្នុងសម័យព្រះពុទ្ធជាម្ចាស់ នៅប្រទេសចិន មានទស្សនវិទូម្នាក់នាម ខុង ជឺ ។ អ្នកប្រដៅសាសនាគ្រិស្តជាតិអឺរ៉ុប ដោយអាននាមរបស់លោកមិនច្បាស់ ក៏សរសេរនិងអានថា កុងហ្វូយស៊ីយុស (Confucius) ។ ទស្សនវិទូចិននេះ កើតនៅឆ្នាំ៥៥១ មុនគ.ស.ក្នុងខេត្តលូ (Lou=គឺជារដ្ឋមួយនៅប្រទេសចិនជំនាន់ដើម)។ អស់រយៈពេល ៥០០ឆ្នាំ ខេត្តលូ ព្រមទាំងខេត្តជិតខាងខ្លះមានអំពើចលាចល និងមានការប្រព្រឹត្តអំពើអសីលធម៌ ដែលនាំឱ្យខេត្តអាប់អោនជាខ្លាំង ។ នាឆ្នាំ៥០១ មុនគ.ស. ខុង ជឺ ត្រូវបានតែងតាំងជា អភិបាលខេត្តលូ រួចជាមន្ត្រីរបស់ព្រះរាជា ។ ព្រះគ្រូបានដឹកនាំគ្រប់គ្រងខេត្ត ទៅតាមគន្លងសីលធម៌ ដែលងាយស្រួលអនុវត្ត ប្រកបដោយសុភវិនិច្ឆ័យ ។ វិធីនេះ មានតែមួយគត់ គឺមុនដំបូងព្រះរាជាត្រូវមានគុណធម៌ (vertus morales) ។ រដ្ឋមន្ត្រីអ្នករាជការទាំងឡាយនឹងត្រូវវិនិច្ឆ័យជូនរង្វាន់ទៅលើគុណធម៌ដែលប្រព្រឹត្ត។ប្រជាជនត្រូវតែគោរពកោតខ្លាច អោនលំទោន អ្នកគ្រប់គ្រងថ្នាក់លើ ។ របៀបគ្រប់គ្រងនេះមិនយកទ្រឹស្តីសាសនាមកលាយឡំទេ គឺឯករាជពីសាសនា។គាត់ចង់ឱ្យម្នាក់ៗស្គាល់ករណីយកិច្ចរបស់ខ្លួន និងបំពេញដោយត្រឹមត្រូវ ។ គាត់បានមានប្រសាសន៍ថា « នរណាមិនទាន់ប្រព្រឹត្តបានតាមគន្លងធម៌ត្រូវយកអស់កម្លាំងកាយចិត្តហាត់

ពត់ឱ្យបានជាអ្នកត្រឹមត្រូវ ។ នេះគឺស្រេចតែទៅលើឆន្ទៈប៉ុណ្ណោះ » ។

ក្រោមការគ្រប់គ្រងតាមរបៀបនេះ គេបាននិយាយថា ការរំជើបរំជួលបានស្ងប់ស្ងាត់ទៅ ហើយអំពើពាលាអាវាសែក៏បាត់ទៅដែរ ក្នុងពេលតែប៉ុន្មានខែក្រោយមក ។

ប្រាំសតវត្សមុនយេស៊ូគ្រិស្តព្រះគ្រូខុងជឺបានមានប្រសាសន៍ ដែលគេទុកជាក្បួនប្រចាំជីវិតត្រូវតែគោរពដូចតទៅនេះ ៖ «ចូរអ្នកកុំធ្វើឱ្យសោះដល់អ្នកដទៃនូវអ្វីៗដែលអ្នកមិនចង់ឱ្យអ្នកដទៃធ្វើមកលើខ្លួនអ្នកវិញ» (Ne fait pas à autrui ce que tu ne voudrais pas qu' on te fit ) ។ ពាក្យទូន្មានរបស់ព្រះគ្រូ ខុង ជឺ ថ្វីបើកន្លងមករាប់សតវត្សមកហើយក៏នៅតែត្រូវពិតតតខ្វោះមកទល់សព្វថ្ងៃ នេះ និងជាភស្តុតាងមួយ ដែលអ្នកផងស្គាល់ព្រះគ្រូថាជាមហាបុរសមួយរូបដែលបានទូន្មានក្រមសីលធម៌ដ៏ល្អពិតៗ ។

ជាបន្តបន្ទាប់មក ព្រឹទ្ធាចារ្យចេះតែបន្តទូន្មានកូនចៅរៀងរហូតមក ដើម្បីឱ្យសង្គមនីមួយៗ មានច្បាប់សីលធម៌ អនុវត្តត្រឹមត្រូវ ចៀសវាងកុំឱ្យមនុស្សធ្លាក់ទៅជាសត្វតិរច្ឆាន ប្រកាប់ប្រចាក់គ្នាឥតត្រាប្រណី ឱ្យមនុស្សដឹងល្អ ដឹងអាក្រក់ ដឹងខុស ដឹងត្រូវ ឱ្យមនុស្សជាតិរស់រានមានជីវិតជាយូរអង្វែងតទៅ ។ សង្គមមនុស្ស ទោះស្ថិតនៅកន្លែងណាក្តី ហើយមានលក្ខណៈសម្បត្តិរស់នៅយ៉ាងណាក៏ដោយ ក៏បានបង្កើតក្រមសីលធម៌និងបានវិនិច្ឆ័យមនុស្សដែលមិនគោរពក្រមសីលធម៌ ។ បើមិនដូច្នោះទេ ច្បាប់ព្រៃនៅតែអនុវត្តដដែលហើយសង្គមមនុស្សនឹងរលត់រលាយជាមិនខាន ។ ជាតឹកតាងស្រាប់ ជនជាតិ អ៊ូកា នៅប្រទេសអេក្វាទ័រ (Equateur) សព្វថ្ងៃ ផុតពូជអស់ប្រាំភូមិ ហើយនៅសល់តែពីរភូមិ ដោយមកពីជនជាតិរស់នៅភូមិទាំងប្រាំនោះ មិនគោរព និង អនុវត្តក្រមសីលធម៌ ។

ជាក់ស្តែងប្រជាជនកម្ពុជា នឹងត្រូវផុតពូជជាខ្មែរ ប្រសិនបើរស់នៅមួយឬពីរឆ្នាំបន្តពីឆ្នាំ១៩៧៨ មក ក្រោមរបបខ្មែរក្រហមប្រល័យពូជសាសន៍ ដែលបានចែងថា «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត នៅសល់តែម្នាក់ ក៏ធ្វើបដិវត្តន៍បានដែរ» ។ សំដីនេះជាសំដីរបស់អ្នកមានទស្សនៈងងឹតស្លុង ទៅដោយមហិច្ឆតាឥតព្រំដែន ចង់ខ្ពស់ចង់ថ្កើងសម្លាប់ឱ្យអស់នរណាដែលត្រូវសង្ស័យថាក្បត់ នរណាដែលហ៊ានតវ៉ា នរណាដែលហ៊ានលួចជំឡូងមួយមើម។ ពុទ្ធ-សាសនាជាឈើងសង្គម ដោយឃើញតែ «មហាអស្ចារ្យ មហាលោតផ្លោះ ភ្លេចអស់តម្លៃជាសារវន្តនៃមនុស្ស ចាត់ទុកសាសន៍ឯងជាសត្រូវ ។ នៅពេលនោះ (១៩៧៥ - ១៩៧៨) អ្នកដឹកនាំគ្រប់គ្រងគ្រប់ជាន់ថ្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យគ្មានសីលធម៌ក្នុងខ្លួនឡើយ ។

ក្រមសីធម៌សង្គម - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

## តុណ្ហីភាពរាត្រី

ធម្មជាតិនិទ្រាស្ងាត់ជ្រងំ មាន់រងាវយំពុល្វឹងល្វើយ
ខ្យល់បក់ផាងដូងយោលទន់ផើយ រំភើយបក់ផាត់ក្លិនម្លិះលា។
ព្រះចន្ទឈៀងគងភ្នំខ្មៅវែង មេឃខ្ពស់ធំធេងវែងស្អាតថ្លា
សន្សើមប្រោះព្រំចុងព្រឹក្សា ហៅសែនសុខាក្នុងរាត្រី។
តែក្នុងចិត្តខ្ញុំមានកង្វល់ រូបរឹតគិតដល់ត្រួយនារី
រូបនាងខ្ទុតតាមគ្រប់ទិសទី នាំឱ្យរក់រីអស់អង្គកាយ។
ព្រលឹងស្រមៃឃើញវរលក្ខណ៍ មានភក្ត្រញញឹមស្រស់ពព្រាយ
ថៃមព្ទសំដីនាងនិយាយ លៃបខាយពិរោះជាប់ពិសម័យ។
ដូចឃ្មុំស្រវឹងក្លិនបុប្ផា ហើយហើរឆ្លៀវឆ្លាកណ្ដាលថ្ងៃច័ន្ទ
ខ្លួនបងស្រវឹងនឹងមាសថ្លៃ នឹករកមមៃគ្មានពេលលស់។
ជន្លេនម្ដេចហ៊ានស្រលាញ់ផ្កាយ ខ្លួនតូចទាបឆ្ងាយម្ដេចឈោងខ្ពស់
ម្ដេចមិនមើលទ្រព្យមើលកិត្តិយស សញ្ជាតិទាំងអស់សុទ្ធខុសគ្នា។
គ្មានអ្វីគួរឱ្យសង្ឃឹមបាន ស្រលាញ់បំពាននាំខ្លោចផ្សា
គប្បីខំប្រឹងតែសិក្សា សម្រេចកាលណាទើបហៅគាប់។
តែទោះគិតឃើញត្រូវដូចម្ដេច ស្នេហាពន្លិចសង្កត់ជាប់
ឱខ្លួនខ្ញុំអើយសែនអភ័ព្វ ទុក្ខច្រើនស្រទាប់អីម្ល៉េះទេ! ។
ធម្មជាតិដេកលក់ដោយសុខុម មាត់មាន់រងំដូចបំពេរ
ខ្យល់ប្រានផាងដូងឱ្យយោលទេរ ជួយបក់បំបែរក្លិនចំប៉ា។
លោកខែលិចក្រោយភ្នំខ្មៅស្ដើង ពពកមីរឡើងក្នុងមេឃា
សន្សើមស្រោចស្រប់ពសុធា ហៅសែនវេទនាក្នុងចិន្តា។

មាលាដួងចិត្ត - នូ ហាច ( ១៩៧២ )

## កម្រងនវកថា : មួយពព្រិចភ្នែក !

ដំណើររឿងជាទំពក់ថ្កក់គំនិតផ្សេងៗ ។

រសៀលថ្ងៃមួយនោះម៉ោងប្រមាណពីរ។មេឃភ្លឺថ្លាស្រឡះផេង។ខ្យល់ស្ងប់កម្តៅភាយ។រដូវភ្លៀងជិតផុតទៅហើយ។ខ្ញុំអង្គុយផឹកកាហ្វេទឹកកកនៅក្នុងហាងមួយ ជិតមជ្ឈមណ្ឌលនិពន្ធសៀវភៅសិក្សា រំពេចនោះ ខ្ញុំស្រាប់តែភ្ញាក់ក្រញាង ដោយ អា យន មិត្តចាស់របស់ខ្ញុំដើរសំដៅមកគុខ្ញុំហើយដាក់គូថអង្គុយទល់មុខខ្ញុំ ។ ខ្ញុំពោលទៅកាន់គាត់ថា ៖

- ឃី ! អាសម្លាញ់យនទេតើ អញស្មានតែឯងស្លាប់បាត់ទៅហើយ គិតទៅយើងបែកគ្នាជាងប្រាំឆ្នាំហើយ តាំងពីបែកភ្នំពេញមក។ឯងចង់ញ៉ាំអ្វីដែរ ហៅទៅ ?

- កាហ្វេទឹកដោះគោទឹកកកមួយ !

- ចុះឥឡូវឯងធ្វើការអី ហើយរស់នៅឯណាដែរ ?

- អ៊ុំ ! គ្មានអ្វីក្រៅពីធ្វើគ្រូបង្រៀនទេ ចំណែកផ្ទះវិញនៅតាមវិថីសុកហុក ខាងកើតផ្សារអូឫស្សី ។ ចុះឯងវិញធ្វើអ្វី នៅឯណាដែរ ?

- ជាអ្នកនិពន្ធសៀវភៅសិក្សា នៅជិតនេះទេ ខាងលិចក្រសួងអប់រំ ផ្លូវ៣១០ កែងវិថីប៉ាស្ទ័រ ។

-និយាយអញ្ចឹងទៅកាលសម័យប៉ុលពតឯងត្រូវពួកវាជន្លៀសទៅនៅឯណាដែរ ?

- ខេត្តបាត់ដំបង ស្រុកគាស់ក្រឡ ឃុំដូនបា ភូមិព្រៃភ្វាស ។

- ឯគ្នានៅស្រុកមោងឫស្សី ឃុំពេជចង្វា ភូមិប៉ែន ។នឹកដល់រឿងភូមិប៉ែន គ្នាឡើង ព្រឺសម្បុរគីង្គក់តែម្តង ។

- ឯងជួបរឿងហេតុអីកើតឡើងឬ ?

-កាលណោះត្រពាំងឫស្សីពោរពេញទៅដោយទឹកថ្លាឆ្វង់ ឆ្លុះដល់បាត ។ មនុស្សស្វាត់ ។ នៅឯមាត់ត្រពាំងរិតតែស្ងាត់ទៅទៀត រហូតគ្មានភ្នែកណាចាប់ភ្លឹក ឬនឹកឃើញថា ខ្ញុំកំពុងត្រាំក្នុងទឹក ផ្អែមត្រជាក់តែម្នាក់ឯងនោះផង ។ អារម្មណ៍ខ្ញុំហោះទៅឆ្ងាយ ... ទៅក្រៅការដ្ឋានទំនប់ទឹក ដែលមិនដឹងជាពេលណាបានចប់សព្វគ្រប់។គំនិតនិងចិត្តក៏ផ្ចិតទៅរឿងផ្សេងៗយ៉ាងជក់ជាប់ដែររហូតខ្ញុំគ្មានដឹងថាស្រីម្នាក់មកឈរក្បែរកំពង់ទឹកខ្ញុំតាំងអំពីពេលណា។គេអាយុប្រហែលម្ភៃឆ្នាំក្រាស់ សម្បុរអាចម៍ផ្វា ទឹកមុខជាអ្នកមានឫកពាមិនសូវស្លូត សាច់ឈាមមិនសូវចុះចំណោមស្លៀកសំពត់ខ្មៅចោមពង់ប្រុងចុះមុជទឹកក្នុងកំពង់ទឹកជាមួយគ្នា ក្នុងពេលដំណាលខ្ញុំ ។

ផ្លាស់មកពីការដ្ឋានផ្សេងនាងត្រូវអង្គការចាត់ឱ្យទទួលខុសត្រូវការដ្ឋានសាងសង់ទំនប់ទឹកភូមិប៉ែននេះបានមួយអាទិត្យមកហើយ។ខ្ញុំដូចជាគ្មាននិស្ស័យនឹងនិយាយរកតាំងពីចូលមកទីនេះម្ល៉េះ ។ នាងមានឈ្មោះថា សមមិត្តនារី យឿត ។ ពាក្យដែលនាងនេះតែងពោលជាមួយអ្នកផង បញ្ជាក់ថាគេចូលចិត្តអួតក្អេងក្អាង ហើយមានគំនិតគិតត្រឹមអាត្មាឯងមិនតិច។ មនុស្សយើងខ្លះឃើញភ្លាម ទ្រឹស្តីភ្លាម ហើយប្រសិនបានទាក់សំដីគ្នាថែមបន្តិចផងជួននាំឱ្យខ្ពើមតែម្តងក៏មាន ។ ខ្ញុំធ្លាប់ជជែកជាមួយគេពីរបីដងលេងដែរ តែនិយាយពេលណាទ្រលាន់ពេលនោះ ហើយជជែកច្រើនឡើង ចិត្តក៏កាន់តែក្តៅខ្លាំងឡើង។

ថ្ងៃមុន ខ្ញុំបានឃើញនាងនោះ បញ្ជាឈ្លបឃុំដេញបាញ់តួកុនម្នាក់ ឈ្មោះ ជិន សារិ ដែលគេស៊ើបដឹងថាជាគ្រូហាប់គីដូបីដាន់ ។ ជនរងគ្រោះ រត់កាត់ហ្វូងពលករ ពួកឈ្លបពីតតែបាញ់រះពីក្រោយ ។ មនុស្សម្នាក្រាបរដូករដែលលើខ្នងទំនប់ ។ ទីបំផុតជនរងគ្រោះ ត្រូវពួកវាបាញ់សុះសាច់ ដួលដេកចង្រ្កាង ស្លាប់នៅជើងទំនប់ គួរឱ្យអនិច្ចា ។

ខ្ញុំដុះគំនិតចង់ប្រាប់កនាងយឿតជ្រមុជទឹក ត្រពាំង ... មែន មើលៗទៅ ខ្ញុំមានកម្លាំងលើសនាង ច្រើនណាស់ ។ « ចម្ងាយពីកន្លែងខ្ញុំឈរក្នុងទឹក ទៅ កន្លែងនាងឈរងូត ប្រហែលជិតពីរម៉ែត្រ បើខ្ញុំលប សន្សឹមៗពីខាងក្រោយ រួចយកក្រមារិបកនាងពេញ ទំហឹង (ខ្ញុំគិត) គឺមិនអាចស្រែកឱ្យនរណាដឹងឮទាន់ ជាដាច់ខាត ...

ហេតុផលរយពាន់បានផុសចេញឯងៗក្នុងវិនាទី ដ៏ខ្លី ... « ល្មមសម្លាប់មួយដែរ ... នាងនេះមិនមែនជា មនុស្សទេ ... ជាឆ្កែចចក រស់នៅនាំធ្ងន់ផែនដីទទេ ... ស្លាប់ក៏គ្មានខាតគេឯងដែរ។គេអាចយល់និងជឿបាន ថា នាងលង់ទឹក ។ អ្នកផងអាចស្មានថា ព្រោះនាង ផុងជើង ឈ្លក់ទឹកស្លាប់ ព្រោះនាងត្រូវខ្មោចទឹកទាញ ព្រោះបាបកម្មគន់ហាន់ ដែលនាងបានសាងស្ទើររាប់ ភ្លេច។ខ្ញុំគេចចេញពីទីកន្លែងនោះយ៉ាងប្រញាប់ហើយ បើមានគេសួរនាំស្រេចតែថាមិនបានដឹងមិនបានឃើញ តែម្តង ។ បើគេធ្លាប់ស្គាល់ខ្ញុំជាមនុស្សស្លូតផង គេ លែងចោទប្រម៉ែថា « ខ្ញុំហ៊ានសម្លាប់មនុស្សទៅទៀត ... » ។

ទេ ! ខ្ញុំនឹងទៅសារភាពដាក់អង្គការ ។ ខ្ញុំនឹង ពន្យល់គណៈសហករណ៍ពីហេតុដែលនាំឱ្យខ្ញុំលា បាតដៃដ៏មានតម្លៃទាំងពីរទៅរិតកនាងនោះតែមួយរិប ឱ្យនាងនោះឃើញឋាននរក ។ ល្ងាចនេះ ឬយប់នេះ គេនឹងចងស្លាបស្លេកខ្ញុំតឹងស្លឹត ហើយគេបណ្តើរខ្ញុំ ទៅកាន់ព្រៃល្បោះក្បែរភូមិ ។ ខ្ញុំនឹងត្រូវកម្ទេចដោយ វាយក្បាលនឹងត្បូងចប។ប្រពន្ធខ្ញុំកូនខ្ញុំមុខជាខាំមាត់ យំ ទាំងក្រហល់ក្រហាយពេញដើមទ្រូង ។គេនឹងមិន ហ៊ានស្រែករកទេវតាឱ្យជួយឡើយ ។

អង្គការនឹងបើកអង្គប្រជុំ ប្រកូកប្រកាសប្រាប់ អ្នកស្រុកអ្នកភូមិថា « ខ្ញុំនេះជាខ្មាំង ជាសេអ៊ីអា ជាកា ហ្សេបេ ... ឥឡូវអង្គការបញ្ជូនឱ្យទៅរាស់ដីបាត់ទៅ ហើយ » ។ ពាក្យប្តេជ្ញា កម្ទេចខ្មាំងបង្កប់ ស៊ីរូងផ្ទៃក្នុង មុខជាគេស្រែកខ្លាំងៗ ដោយក្តាប់ដៃស្តាំលើកឡើង លើ ។ ប៉ុន្តែ បើគេមិនយកខ្ញុំទៅវាយចោលភ្លាមៗទេ គេនឹងចងដៃខ្ញុំយ៉ាងតឹង រួចបណ្តើរយកទៅដាក់ខ្នោះ ជើងបន្ថែមទៀត នៅក្នុងមន្ទីរឃុំ ឃាំង (គុក) ។ ខ្ញុំ ជាប់គុកក៏រស់ដែរ តែរស់រង់ចាំគេយកទៅកប់ចោល តែប៉ុណ្ណោះ ។ ខ្ញុំគិតថា ករណីទីមួយវាឆាប់បាត់ការ ឈឺចាប់ជាង ចំណែកករណីទីពីរ វាឈឺចាប់ពើតផ្សារ រ៉ាំរ៉ៃយូរ។ស្លាប់ដឹងតែស្លាប់ហើយគ្មានការលើកលែង ទេព្រោះពាក្យស្លោករបស់អង្គការចែងច្បាស់ណាស់ថា « សូវសម្លាប់ច្រឡំ កុំឱ្យខ្មាំងរត់រួច » ។ ចុះនេះខ្ញុំមក សារភាពត្រង់ៗថា ខ្លួនជាឃាតកសម្លាប់កម្មាភិបាល របស់អង្គការទៀត រឹតតែច្បាស់ចែសដូចថ្ងៃអញ្ចឹង គឺ ត្បូងចប ឬគល់ឬស្សី ។

ខ្ញុំចង់តាំងខ្លួនជាចៅក្រម...តាមពិតខ្ញុំមិនមែន ជាចៅក្រមទេ។ខ្ញុំចង់បញ្ជាក់ឱ្យមនុស្សរាល់ម៉ឺនសែន នាក់ដឹងថាមានខ្ញុំមួយដែរតែអង្គការក៏បញ្ជាក់មកវិញ បានថា អង្គការមិនអាចមាននរណាប៉ះពាល់បានទេ ...តែហ៊ានគឺខ្មាំង ។ អង្គការ ឬអារកង់ ជារឿងមួយ ទៀត ។ មានប្រយោជន៍អី នឹងបញ្ជាក់ថាមានខ្ញុំមួយ ដែរ បើខ្ញុំមានដោយមិនបាច់បញ្ជាក់ ស្រេចទៅហើយ នោះ ...។

ខ្ញុំនឹកដល់រឿងរាមកេរ្តិ៍ ។ ការលបរិបកគេពី ក្រោយខ្នងបែបនេះគឺដូចព្រះរាមលបបាញ់ពាលីបេះ បិត...ប្លែកត្រង់ពាលីមិនទាន់ស្លាប់ភ្លាមនៅឆ្លើយស៊ក សងឱ្យព្រះរាមយ៉ាងក្លាហាន ផ្សេងពីនាងយឿតដែល បាត់មាត់ឈឹងប៉ុណ្ណោះ ។

បើខ្ញុំសម្លាប់គេម្តាយឪពុកគេព្រមទាំងបងប្អូន គេ យ៉ាងតិចក៏ពីរឬបីនាក់ មុខជាកើតទុក្ខ...កើតទុក្ខ ដោយអត់ដឹងខ្លួនមុន ។ ខ្ញុំនឹងមានឈ្មោះថា ជា អ្នកបង្កើតជនរងទុក្ខ ។ អង្គការមុខជាត្រូវចេញបញ្ជា ថ្មីហាមប្រាមយ៉ាងតឹងរឹងដល់បណ្តាអ្នកបញ្ញើក្អែកដូច រូបខ្ញុំលែងឱ្យចេញដើរពេលម៉ោងស្អុយបានរកឆ្កឹះឆ្អៀល ក្តាម បេះបោចស្លឹកឈើ មុជទឹក ។ ខ្ញុំនឹងមានឈ្មោះ ថា ធ្វើឱ្យគេរងទុក្ខ ។ កូនខ្ញុំ ប្រពន្ធខ្ញុំ ម្តាយឪពុកខ្ញុំ ញាតិខ្ញុំ និងមិត្តខ្ញុំ គ្នាអត់ដឹងខ្លួនទេ តែគ្នាត្រូវរងគ្រោះ ដោយការតាមដានឈ្លបយកការណ៍ ព្រោះតែខ្ញុំទាំង

អស់ ។ អង្គការបង្កើនសន្តិសុខកាន់តែខ្លាំង ហើយការកម្ទេចកាន់តែមមាញឹកបន្ថែមការភ័យខ្លាចដល់ប្រជាជនជន្លៀសដូចគ្នា កាន់តែធ្ងន់ធ្ងរឡើង ។ ទាំងអស់នេះសុទ្ធតែជាផលវិបាកអាក្រក់នៃទង្វើមួយពព្រិចភ្នែករបស់ខ្ញុំ ។ ទេ ! ទេ ! ធម្មជាតិបានផ្ដល់ដៃដ៏ល្អប្រកបដោយម្រាមរហ័សប្រិល និងប៉ិនប្រសប់មកឱ្យខ្ញុំ បើខ្ញុំយកទៅជ្រលក់ឈាមមនុស្សជោកស្រឡាបក្រហមច្រាល នោះខ្ញុំនឹងទៅជាធ្វើឱ្យអ្នកផងអោធម្មជាតិ គឺធ្វើឱ្យធម្មជាតិរងគ្រោះ ។ ទេ ! ទេ! ជីវិតមិនមែនរស់នៅ ដើម្បីធ្វើឱ្យគេរងគ្រោះជាដាច់ខាត !

ខ្ញុំសម្លឹងដៃទាំងពីរគ្មានព្រិច ។ ខ្ញុំសម្លឹងទៅទឹកថ្លាដូចកញ្ចក់ឆ្លុះឃើញមុខខ្ញុំ ។ ខ្ញុំមើលរាងស្រឡះស្រឡូនរបស់សមមិត្តនារីឃៀតដែលគ្របផ្ទឹបដោយសំពត់ទទឹក ។ ខ្ញុំមើលពន្លឺព្រះអាទិត្យចាំងព្រាកៗលើផ្ទៃទឹកត្រពាំង អង្កាញ់ៗ ។ សំលេងចម្លែកមួយហាក់បំពងម៉ាត់ៗ ដាក់សោតិន្ទ្រីយារម្មណ៍ខ្ញុំ ដែលមិនច្បាស់ជានៅក្នុងខ្លួន ឬក៏មិននៅនោះផង : «បន្តិចទៀត ឯងស្លាប់ហើយ នាងឃៀតក៏ដែរ អ្នកដទៃក៏ដែរ ព្រោះនៅក្បែរចង្កូមយមបាលទាំងអស់គ្នា ។ គ្មាននរណាការពារសន្តិសុខឯងបានទេ ។ បួនដប់ម្ភៃឆ្នាំទៀត ឬសាមសិបឆ្នាំទៀតយ៉ាងយូរ ! ឯងមើលឃើញទេ ... ឯងភ័យទេ ... ជីវិតក្រោយពីរស់ គឺលែងរស់ ... គឺទទេ ... បើមិនទទេ ក៏មិនដឹងទៅជាអ្វីដែរ ... បើឯងដឹង គឺដឹងត្រឹមមិនដឹងឯងទៅជាអ្វីប៉ុណ្ណោះ ។ ឯងគិតមើល...សែសិបឆ្នាំទៀតឯងលែងជាឯងហើយ...ឯងគួរញញឹមដាក់គ្នាឱ្យហើយ អាណិតគ្នាឱ្យហើយ ស្រឡាញ់គ្នាឱ្យហើយ ជួយគ្នាឱ្យហើយ ... ទាន់មានពេល ... ទាន់មិនទាន់ទទេ ។ ឯងជឿយើងទេ ... អាណិតនាងឃៀតទេ ឬយល់ថាយើងឃោសនា ? ជឿមិនជឿតាមតែឯងគិតយល់ចុះ តែពេលដែលឯងត្រូវទទេកាន់តែខិតជិតហើយ...ហើយមានតែមច្ចុរាជមួយគត់ ដែលមិនក្លាយជាទទេ ... » ។

ខ្ញុំក៏ភ្ញាក់បន្តិច ខំតាមដានឱ្យដឹងថា សំលេងម៉ាត់ៗនេះ ជារបស់អ្នកណា និងរត់មកពីណា ... តែមិនទាន់បានអ្វីផង វាក៏រលត់ទៅ ដោយគ្មានលាន់ឮជាថ្មីសោះទោះខ្ញុំសុំយ៉ាងណាក្ដី ។ ខ្ញុំជ្រមុចក្បាលចូលទៅក្នុងទឹកមួយសន្ទុះធំផុសឡើងស្វាងខួរបន្តិចបង្អើបភ្នែកឡើង ឃើញអ្នកសម្បុរអោចម៍ថ្លា យកដៃក្បង់ទឹកមកលុបមុខបែរក្រោយដើរឃើតៗឡើងពីកំពង់ឈរឱ្យខ្នងមកខ្ញុំ យកក្រមាចោមពង់ រលាស់សំពត់តិបៗ ពាក់អាវទ្រនាប់ និងពាក់អាវសើមីខ្មៅពីលើ ដើរចេញពីទីនោះដោយគ្មានដឹងបន្តិចថាមុននេះខ្លួននិះនឹងស្លាប់ ។ ខ្ញុំឈរទ្រឹង ... ខ្ញុំក្ដាប់ដៃ ... ខ្ញុំខាំមាត់ ... ខ្ញុំសម្លឹងទៅឆ្ងាយ ខ្ញុំងាកមកវិញ ឃើញគេដើរទៅកាន់តែឆ្ងាយ ។ ខ្ញុំគ្រវីក្បាលរលាស់សក់ រំកិលខ្លួនក្នុងទឹកសូរព្ធ្លូកៗ រួចឈានជើងឡើងលើមាត់ត្រពាំង ស្នូរជួងពលកម្មលាន់គ្រលួចចេញពីការដ្ឋាន ខ្ញុំភ្ញាក់ដូចគេកន្ត្រាក់ថា « ជីវិត... ជីវិតអាចស្លាប់ដោយនឹកស្មានមិនដល់...ខ្ញុំមុននេះបានស្លាប់ជាមួយអ្នកនេះក្នុងមួយពព្រិចភ្នែក ដោយមិនអាចត្រឡប់វិញឡើយ...» ។ ខ្ញុំប្រញាប់យកក្រមាមកទទូរស្រូតតាមពីក្រោយអ្នកដែលខ្ញុំទ្រឹស្ដពីមុននេះហើយខ្ញុំគិតថានឹងខំសើចដាក់នាងឱ្យបានស្មោះជាលើកទីមួយ...មុននឹងត្រូវ...។

ខ្ញុំដាក់ប្រាក់ថ្លៃកាហ្វេលើតុ ។ យើងដើរចេញមកខាងក្រៅហាង ហើយចាប់ដៃលាគ្នា ទាំងវាចាថា : « ពេលក្រោយជួបគ្នា » ។

**លំនឹកពីអតីត ២០២៣**

**បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ថុង**



ប្រាសាទស្រស់ព្រះ
ស្ថិតនៅក្នុងភូមិសំបូរ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ

